**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# បត្យាប័ន

ស្រាវជ្រាវចាប់ពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨

តាក់តែងឡើងដោយ

និស្សិតឈ្មោះ ៖ **សុខ ឫទ្ធី**

**កុល កលរក្សា**

សាស្ត្រាចារ្យណែនាំ

លោក **រុន ពណ្ណារិទ្ធ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៨

ឆ្នាំចូលសិក្សា ២០១៤

ឆ្នាំសរសេរសារណា ២០១៨

# លិខិតថ្លែងអំណរគុណ

យើងខ្ញុំទាំងពីររូបឈ្មោះ **សុខ ឧុទ្ធី** និង **គុល គលរក្សា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជំនាន់ទី១៨ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិង វិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៧ និង ២០១៨ ។ យើងខ្ញុំបានសរសេរសារណាបញ្ចប់ការសិក្សា ដោយជ្រើសយកប្រធានបទស្តីពី "**បត្យាប័ន**" ។

## យើងខ្ញុំសូមគោរពលំអោនកាយវាចាចិត្តសម្តែងនូវគារវកិច្ច និងមហាកត្តញ្ញូដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ

**លោកឪពុក សុខ សម្បត្តិ** និង **អ្នកម្តាយ សុខ ច័ន្ទដាវី** **លោកឪពុក គុល ផល្លី** និង **អ្នកម្តាយ សឿង សុភា** ។ កូនសូមអនុញ្ញាតសម្តែងនូវការដឹងគុណចំពោះ គុណូបការៈដ៏ធំធេងបំផុតមិនអាចកាត់ថ្លៃបាន របស់លោកឪពុកអ្នក ម្តាយទាំងទ្វេ ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ទំនប់បំរុង កូនៗទាំងពីរតាំងពីពេលនៅក្នុងពោះ រហូតដល់កូនបានធំដឹងក្តី។ រយៈពេល ២០ជាងឆ្នាំ ដែលកូនបានរស់នៅជាគ្រួសារតែមួយជាមួយលោកឪពុកអ្នកម្តាយ លោកទាំងទ្វេតែងតែទូន្មានប្រៀនប្រដៅ ផ្តល់ដំបូន្មានល្អៗ លើកទឹកចិត្ត ថ្នាក់ថ្នម ថែរក្សាការពារកូនៗ អស់ពីកម្លាំងកាយចិត្ត ដើម្បីឲ្យកូនក្លាយជាមនុស្សប្រកបដោយកិត្តិគុណ សីលធម៌ គុណធម៌ ដ៏ប្រពៃបំផុត។ មិនតែប៉ុណ្ណោះ អ្នកមានគុណទាំងពីរបានតស៊ូខិតខំប្រឹងប្រែងពុះពារទាំងយប់ថ្ងៃដោយកម្លាំងញើសឈាម ដើម្បីធ្វើជាស្ពានផ្គត់ផ្គង់ និងបំពេញរាល់តម្រូវការខ្វះខាតរបស់កូនៗទាំងគ្រឿងបរិភោគ និងសម្ភារៈប្រើប្រាស់សព្វបែបយ៉ាងព្រោះតែចង់ឲ្យកូនមានអ្វីៗដូចគេ ។ តំណក់ញើសដែលអ្នកមានគុណបានតស៊ូដោយមិនត្អូញត្អែរនេះ បាននាំកូនរហូតដល់កូនបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ ហើយកូនៗពិតជាមិនអាចបំភ្លេចបាននូវគុណតម្លៃដ៏ថ្លៃថ្លារបស់លោកដែលតក់ជាប់ក្នុងបេះដូងរបស់យើងខ្ញុំជារៀងរហូតលុះក្ស័យសង្ខារ។

ដូចនេះកូនទាំងពីរសូមលើកហត្ថាទាំងទ្វេលំអោនកាយក្រាបសំពះដល់បាតជើងដើម្បីសម្តែងនូវកត្តញ្ញូចំពោះគុណូបការៈដ៏ធំធេងមួយនេះ ព្រមទាំងបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោកតាមថែរក្សាលោកឲ្យប្រកបតែសេចក្តីសុខ សុខភាពមាំមួន និងភាពចុំចើ្រងរុងរឿងជាដរាបតទៅ។

**សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេច កិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** រួមជាមួយសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជាគ្រប់ជាន់ថ្នាក់ ដែលបានបង្កឲ្យមានកាលានុវត្តភាពដ៏គាប់ប្រសើរ និងជម្រុញឲ្យសង្គមមានការអភិវឌ្ឍន៍លើគ្រប់វិស័យ និយាយជារួម និងសម្រាប់វិស័យអប់រំ និងការសិក្សាស្រាវជ្រាវ

និយាយដោយឡែក។ តាមរយៈការដឹកនាំដ៏ឈ្លាសវៃ និងខិតខំប្តូរផ្តាច់ បង្រួបបង្រួមជាតិ របស់សម្តេច បានធ្វើឲ្យប្រទេសកម្ពុជាទទួលបាន សុខសន្តិភាព ស្ថេរភាព ហើយធ្វើឲ្យនិស្សិតទទួលបានការអប់រំខ្ពង់ខ្ពស់គ្រប់គ្នា ជាប្រយោជន៍សម្រាប់ការអភិវឌ្ឍន៍សង្គមកម្ពុជាប្រកបដោយវឌ្ឍនភាពថែមទៀត។

**ឯកឧត្តម លុយ ចណ្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច រួមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក លោកស្រី សាស្ត្រាចារ្យ ដែលបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាព ក្នុងការដឹកនាំ និងពង្រឹងគុណភាពកម្មវិធីសិក្សាដល់និស្សិតគ្រប់ជំនាញប្រកបដោយប្រសិទ្ធិភាពការងារខ្ពស់ ជាពិសេសលើកទឹកចិត្ត និងជម្រុញ ព្រមទាំងជួយតម្រង់ទិសយើងខ្ញុំឲ្យទទួលបានពុទ្ធិច្បាស់លាស់ ដើម្បីក្លាយជាសសរទ្រូងរបស់ជាតិ អាចបម្រើ និងសងគុណចំពោះជាតិបានផងដែរ។

**លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ** និង **លោកស្រី សាស្ត្រាចារ្យ ចាំង ស៊ីណាត** ដែលជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ ព្រោះថាប្រសិនបើគ្មានការចំណាយពេលវេលាដ៏មានតម្លៃ និងកម្លាំងកាយចិត្ត ក្នុងការជួយជ្រោមជ្រែង ផ្តល់យោបល់ ជាគំនិតល្អៗ ត្រួយត្រាយ និងផ្តល់ជាវិធីសាស្ត្រល្អៗ ដល់យើងខ្ញុំទេ នោះសមិទ្ធផលនេះមិនអាចកើតមានឡើយព្រោះគ្មានសមិទ្ធផលណាមួយកើតឡើងដោយឯកឯងទេ។ ការជួយណែនាំ និងផ្តល់ជាបទពិសោធន៍ដ៏មានគុណតម្លៃរបស់លោកគ្រូអ្នកគ្រូកន្លងមក បានបង្រៀនឲ្យយើងខ្ញុំយល់ច្បាស់ពីប្រធានបទមួយនេះ និងស្គាល់ពីសង្គមបានច្រើន ទើបធ្វើឲ្យយើងខ្ញុំសម្រេចបាននូវការតាក់តែងសារណាបញ្ចប់ការសិក្សាប្រកបដោយគុណភាព។

**និស្សិតរៀមច្បង** និង **មិត្តនិស្សិតដទៃទៀត** ដែលបានលើកទឹកចិត្ត គាំទ្រ ផ្តល់ជាបទពិសោធន៍ គំនិតយោបល់ល្អៗ ដែលជម្រុញឲ្យខ្ញុំបាទកាន់តែមានទឹកចិត្តក្នុងការសម្រេចនូវសារណានេះដោយមិនរាថយ ដើម្បីទុកជាវិភាគទានក្នុងការសិក្សាស្រាវជ្រាវផ្សេងៗ ក៏ដូចជាទុកសម្រាប់មិត្តនិស្សិត និងប្អូនៗជំនាន់ក្រោយៗបានសិក្សាបន្ថែមស៊ីជម្រៅលើប្រធានបទនេះ។

មុននឹងបញ្ចប់ យើងខ្ញុំទាំងពីរអ្នកសូមការអនុញ្ញាតដើម្បីបានគោរពបន្ទន់កាយ លើកហត្ថាទាំងទ្វេប្រណម្យបួងសួង និងលំអោនកាយវាចាចិត្តថ្លែងអំណរគុណ និងសម្តែងនូវសេចក្តីដឹងគុណដល់អ្នកទាំងអស់គ្នា ដែលបានរៀបរាប់ខាងលើឲ្យជួបប្រទះតែភាពសុខដុមរមនា មានសុខភាពបរិបូរណ៍ ព្រមទាំងប្រកបការងារអ្វីៗឲ្យបានជោគជ័យប្រកបដោយឧត្តមភាព និងភាពថ្កុំថ្កើងជានិរន្តរ៍។

# អារម្ភកថា

បន្ទាប់ពីយើងខ្ញុំបាននិងកំពុងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល ៤ឆ្នាំកន្លងមកនេះ យើងខ្ញុំបានក្រេបជញ្ជក់ និងទទួលបាននូវពុទ្ធិ ក៏ដូចជាទ្រឹស្តី បទពិសោធន៍ជាច្រើន ទាក់ទងនឹងវិស័យច្បាប់ និងចំណេះដឹងទូទៅផ្សេងៗមួយចំនួនផងដែរ។ ទន្ទឹមនឹងនេះ យើងខ្ញុំចាត់ទុកសាលាជាភូមិកំណើតបង្កើតគំនិត ព្រោះសាលាមិនត្រឹមផ្តល់នូវចំណេះដឹងដល់យើងខ្ញុំប៉ុណ្ណោះទេ ប៉ុន្តែក៏បានផ្តល់ជាគុណធម៌ និងសីលធម៌ដល់យើងខ្ញុំ ហើយធ្វើឲ្យយើងខ្ញុំប្រកាន់ខ្ជាប់នូវវិន័យជាប់ប្រាណជានិច្ច។

ដោយសារតែយើងខ្ញុំជានិស្សិតផ្នែកនីតិសាស្ត្រ ស្របពេលដែលប្រទេសកម្ពុជាយើងកំពុងមានវត្តមានជនបរទេសជាច្រើនចូលមក ជាហេតុធ្វើឲ្យយើងខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងទាក់ទងនឹងការផ្ទេរជនល្មើសពីរដ្ឋមួយទៅរដ្ឋមួយនៅពេលមានបទល្មើសកើតឡើងនៅលើទឹកដីនៃប្រទេសណាមួយ។ ហេតុនេះហើយទើបយើងខ្ញុំបានសម្រេចចិត្តជ្រើសយកប្រធានបទសារណាស្តីពី "**បត្យាប័ន**"។

ម្យ៉ាងវិញទៀត មូលហេតុដែលយើងខ្ញុំជ្រើសយកប្រធានបទនេះទៀតសោត គឺដោយសារនាពេលបច្ចុប្បន្ននេះបទល្មើសកំពុងមានការរីករាលដាលពីមួយថ្ងៃ ទៅមួយថ្ងៃនៅពាសពេញផ្ទៃប្រទេស ក៏ដូចជាប្រទេសដទៃទៀតដែរ។ជាក់ស្តែងមានជនខិលខូចមួយចំនួនបានប្រព្រឹត្តិបទល្មើសរួច តែងតែរត់គេចខ្លួនទៅកាន់ប្រទេសដទៃ ដើម្បីរួចផុតពីការទទួលខុសត្រូវចំពោះមុខច្បាប់។

កាលពីមុន ការចាប់ខ្លួនជនណាម្នាក់ដែលបានរត់គេចខ្លួនទៅកាន់ប្រទេសដទៃ គឺមានភាពលំបាកណាស់ ដោយសារពីមុនប្រទេសកម្ពុជាពុំទាន់មានសន្ធិសញ្ញាបត្យាប័នជាមួយបណ្តាប្រទេសដទៃនៅលើសាកលលោកនោះទេ។ ដោយសារតែមានផលវិបាកច្រើនក្នុងការចាប់ខ្លួនជនល្មើសដែលរត់គេចខ្លួនទៅប្រទេសផ្សេងយកមកផ្តន្ទាទោសបែបនេះហើយ ទើបធ្វើឲ្យប្រទេសកម្ពុជាធ្វើការចុះសន្ធិសញ្ញាបត្យាប័នជាមួយប្រទេសមួយចំនួនដូចជា ប្រទេសចិន ប្រទេសថៃ ប្រទេសឡាវ ប្រទេសកូរ៉េខាងត្បូង ប្រទេសវៀតណាម និងប្រទេសបារាំង។ ក្រៅពីការចុះសន្ធិសញ្ញាខាងប្រាំមួយខាងលើ កម្ពុជាក៏បានចុះកិច្ចព្រមព្រៀងជួយគ្នាទៅវិញទៅមក ជាមួយប្រទេសមួយចំនួនផងដែរដូចជា ប្រទេសអាមេរិក ប្រទេសអូស្ត្រាលី ប្រទេសរុស្ស៊ី ប្រទេសឥណ្ឌា និងប្រទេសបារាំងជាដើម ទាក់ទងនឹងការផ្ទេរទណ្ឌិត និងជំនួយផ្នែកច្បាប់។

មិនតែប៉ុណ្ណោះ ដោយសារតែការធ្វើបត្យាប័ន បានផ្តល់អត្ថប្រយោជន៍យ៉ាងខ្លាំងដល់ប្រទេសនីមួយៗនៅក្នុងពិភពលោកក្នុងការជួយគ្នាទៅវិញទៅមកតាមរយៈសន្ធិសញ្ញា ក៏ដូចជាកិច្ច

ព្រមព្រៀង ដើម្បីទប់ស្កាត់ កាត់បន្ថយបទល្មើសឆ្លងដែន និងបញ្ជូនជនខិលខូចដែលបានរត់គេចខ្លួននោះមកផ្តន្ទាទោសតាមច្បាប់នៃប្រទេសសាមី ទើបធ្វើឲ្យប្រទេសនីមួយៗព្យាយាមបង្កើតទំនាក់ទំនងដើម្បីបង្កើតសន្ធិសញ្ញាបត្យាប័នឡើង។ កត្តាទាំងនេះហើយ ទើបធ្វើឲ្យយើងខ្ញុំទាំងពីរអ្នកបានសម្រេចចិត្តជ្រើសយកប្រធានបទនេះ ដើម្បីសរសេរបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ក្នុងគោលបំណងសិក្សាស្វែងយល់ឲ្យបានស៊ីជម្រៅ និងដើម្បីឲ្យមិត្តនិស្សិតផ្សេងទៀត បានយល់កាន់តែច្បាស់ពីបញ្ហាបត្យាប័ន ក៏ដូចជាផ្តល់នូវចំណេះដឹងបន្ថែមផ្នែកព្រហ្មទណ្ឌផងដែរ។

យើងខ្ញុំទាំងពីររូប មានសេចក្តីសោមនស្សឥតគណនា ដែលទទួលបាននូវការណែនាំ និងដឹកនាំពីលោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និង លោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ក្នុងការស្រាវជ្រាវសារណាលើប្រធានបទដ៏មានសារៈសំខាន់មួយនេះ។ ដើម្បីឆ្លើយតបនឹងសមានចិត្តដ៏ល្អប្រពៃពីសំណាក់លោកគ្រូអ្នកគ្រូ យើងខ្ញុំសូមគោរពថ្លែងអំណរគុណ ដល់លោកគ្រូ អ្នកគ្រូ ដែលបានចំណាយពេលវេលាដ៏មានតម្លៃបំផុតព្រមទាំងកម្លាំងកាយចិត្តមិនខ្លាចនឿយហត់ ក្នុងការចែករំលែកចំណេះដឹង គួបផ្សំនឹងបទពិសោធន៍ដែលយើងខ្ញុំមិនធ្លាប់បានជួបប្រទះកន្លងមក និងការយកចិត្តទុកដាក់ខិតខំប្រឹងប្រែងក្នុងការបណ្តុះបណ្តាល សម្របសម្រួល ជាហេតុធ្វើឲ្យយើងខ្ញុំទទួលបាននូវសមិទ្ធផលដ៏វិសេសវិសាលបំផុតមួយនេះ។

ទោះជាយ៉ាងណាក៏ដោយ ថ្វីបើការសិក្សាស្រាវជ្រាវនេះកើតចេញពីការខិតខំអស់ពីសមត្ថភាពរបស់យើងខ្ញុំទាំងពីរក៏ពិតមែន ប៉ុន្តែយើងខ្ញុំជឿថាការស្រាវជ្រាវនេះនៅមិនទាន់គ្រប់គ្រាន់ឥតខ្ចោះនៅឡើយ ដោយសារមានផលវិបាកច្រើនក្នុងការស្វែងរកឯកសារដែលពាក់ព័ន្ធពីប្រភពផ្សេងៗ និងស្ថាប័នពាក់ព័ន្ធទាំងឡាយ។ អាស្រ័យហេតុនេះហើយ សូម លោក លោកស្រីសាស្ត្រាចារ្យ មិត្តនិស្សិត និងមិត្តអ្នកអានទាំងឡាយ មេត្តាខន្តី អភ័យទោស នូវរាល់កំហុសឆ្គងដោយអចេតនា ហើយយើងខ្ញុំរង់ចាំស្វាគមន៍ជានិច្ចចំពោះការចូលរួមវាយតម្លៃ និងការរិះគន់ក្នុងន័យស្ថាបនាទៅលើប្រធានបទមួយនេះ។

ក្នុងនាមយើងខ្ញុំជាអ្នកសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាសៀវភៅមួយក្បាលដែលអ្នកកំពុងកាន់នេះ នឹងក្លាយជាឯកសារដ៏មានតម្លៃមួយ ក្នុងការផ្តល់ចំណេះដឹងដល់អ្នកមិត្តអ្នកអានទាំងអស់គ្នា និងជួយលើកតម្កើងវិស័យអប់រំឆ្ពោះទៅរកវឌ្ឍនភាពផងដែរ។

រាជធានីភ្នំពេញ,ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៨

សុខ វុទ្ធី កុល កលរក្សា

# មាតិកា

**សេចក្តីផ្តើម** ........................................ ១
**ជំពូកទី១ លក្ខខណ្ឌនៃការធ្វើបត្យាប័នតាមការព្រមព្រៀងរវាងរដ្ឋ និងរដ្ឋ** ........................................ ៦
**ផ្នែកទី១ បត្យាប័នផ្អែកតាមសន្ធិសញ្ញា** ........................................ ៦
១.១. សន្ធិសញ្ញាទ្វេភាគី ........................................ ៧
១.១.១. សន្ធិសញ្ញាទ្វេភាគីជាមួយប្រទេសថៃ ........................................ ៧
១.១.២. សន្ធិសញ្ញាទ្វេភាគីជាមួយប្រទេសចិន ........................................ ៨
១.១.៣. សន្ធិសញ្ញាទ្វេភាគីជាមួយប្រទេសឡាវ ........................................ ៨
១.១.៤. កិច្ចព្រមព្រៀងទ្វេភាគីជាមួយប្រទេសកូរ៉េខាងត្បូង ........................................ ៨
១.១.៥. សន្ធិសញ្ញាទ្វេភាគីជាមួយប្រទេសវៀតណាម ........................................ ៨
១.១.៦. អនុសញ្ញាទ្វេភាគីជាមួយប្រទេសបារាំង ........................................ ៨
១.២. សន្ធិសញ្ញាពហុភាគី ........................................ ៩
**ផ្នែកទី២ បត្យាប័នក្នុងករណីពុំមានសន្ធិសញ្ញា** ........................................ ៩
**ជំពូកទី២ នីតិវិធីនៃការធ្វើបត្យាប័ន** ........................................ ១៣
**ផ្នែកទី១ ព្រះរាជាណាចក្រកម្ពុជាជារដ្ឋដាក់សំណើ** ........................................ ១៤
១.១. សំណើធ្វើបត្យាប័ន ........................................ ១៤
១.២. សំណើចាប់ខ្លួនបណ្តោះអាសន្ន ........................................ ១៧
១.៣. ការសម្រេចចិត្តទៅលើការស្នើសុំ ........................................ ១៧
១.៤. ការអនុវត្តបត្យាប័ន ........................................ ១៩
**ផ្នែកទី២ ព្រះរាជាណាចក្រកម្ពុជាជារដ្ឋទទួលសំណើ** ........................................ ២២
២.១. ការបញ្ជូនពាក្យសុំធ្វើបត្យាប័ន ........................................ ២៣
២.២. ការចាប់ខ្លួន និងឃុំខ្លួនបណ្តោះអាសន្ន ........................................ ២៤
២.៣. សេចក្តីសម្រេចពីបត្យាប័ន ........................................ ២៩
**សេចក្តីសន្និដ្ឋាន** ........................................ ៣៣
**អនុសាសន៍** ........................................ ៣៥
**បញ្ជីឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

បត្យាប័នគឺសំដៅទៅលើនីតិវិធីនៃការបញ្ជូនខ្លួនជនល្មើសពីរដ្ឋមួយទៅរដ្ឋមួយទៀត។ក្នុងន័យច្បាប់ បត្យាប័នគឺសំដៅដល់នីតិវិធីមួយដែលក្នុងនោះមានរដ្ឋមួយជារដ្ឋធ្វើសំណើ ឬរដ្ឋដាក់សំណើ បានធ្វើសំណើទៅកាន់រដ្ឋមួយទៀតដែលជារដ្ឋទទួលសំណើ ក្នុងការស្នើសុំយកជនណាម្នាក់ពីរដ្ឋនោះ ដើម្បីយកជននោះមកចោទប្រកាន់ ឬមកផ្តន្ទាទោស តាមផ្លូវច្បាប់នៃប្រទេសរបស់ខ្លួន។

គោលបំណងនៃបត្យាប័ន គឺត្រូវនាំយកបុគ្គលដែលស្ថិតនៅក្នុងព្រំដែននៃប្រទេសស្នើសុំ ដើម្បីនិងធ្វើការសម្រេចចិត្តអំពីទោស ថាតើមានទោស ឬគ្មានទោស ឬដើម្បីដាក់ទោស។ បត្យាប័នមានតួនាទីយ៉ាងសំខាន់នៅក្នុងការវាយប្រយុទ្ធ របស់អន្តរជាតិប្រឆាំងនឹងឧក្រិដ្ឋកម្ម។ តាមធម្មតា ច្បាប់បត្យាប័នត្រូវផ្អែកទៅលើសន្ធិសញ្ញា ដែលក្នុងនោះមានរដ្ឋពីរព្រមព្រៀងគ្នានៅក្នុងសន្ធិសញ្ញាទ្វេភាគី ដើម្បីយល់ព្រមប្រគល់ខ្លួនជនល្មើសឲ្យគ្នាទៅវិញទៅមក ដោយការចោទប្រកាន់ថា ជាបទល្មើសណាមួយដែលត្រូវចាត់ទុកថា អាចធ្វើបត្យាប័នបានស្ថិតនៅក្រោមកិច្ចព្រមព្រៀងសន្ធិសញ្ញាបត្យាប័ន។

ជាការពិតណាស់ មនុស្សមួយចំនួនធំ ពុំបានយល់ច្បាស់ ថាតើអ្វីជាបត្យាប័នឲ្យពិតប្រាកដនោះទេ។ រហូតមកដល់សតវត្សទី១៨ បត្យាប័នត្រូវបានគេស្គាល់បន្តិចម្តងៗតាមរយៈការបញ្ជូនជនល្មើសពីរដ្ឋមួយទៅរដ្ឋមួយ ដោយពុំមានចងក្រងជានីតិវិធីច្បាស់លាស់នោះទេ។ ជាក់ស្តែងជនល្មើសមួយចំនួន ក្រោយពីបានប្រព្រឹត្តបទល្មើសនៅក្នុងប្រទេសណាមួយហើយ តែងតែរត់គេចខ្លួនទៅកាន់ប្រទេសផ្សេងទៀត ទាំងស្របច្បាប់ និងមិនស្របច្បាប់ដើម្បីរួចផុតពីការទទួលខុសត្រូវតាមផ្លូវច្បាប់។ ហេតុដូច្នេះហើយ ទើបមកដល់សតវត្សទី១៩ ប្រទេសយ៉ាងច្រើននៅលើសកលលោក បានខិតខំប្រឹងប្រែងសហការគ្នា ដើម្បីជម្រុញភាពងាយស្រួល ក្នុងការនាំយកជនដែលប្រព្រឹត្តបទល្មើសមកផ្តន្ទាទោសតាមផ្លូវច្បាប់នៃប្រទេសរបស់ខ្លួន ដោយបានបង្កើតជានីតិវិធីមួយជាក់លាក់ តាមរយៈការចុះសន្ធិសញ្ញារវាងរដ្ឋ និងរដ្ឋស្តីពីបត្យាប័ន។ តាមរយៈការបង្កើតនូវសន្ធិសញ្ញាបត្យាប័ននេះហើយ

ដែលអាចអនុញ្ញាតឲ្យរដ្ឋមួយដែលហៅថារដ្ឋដាក់សំណើ អាចធ្វើការស្នើសុំទៅរដ្ឋមួយទៀតជារដ្ឋទទួលសំណើបានក្នុងករណីដែលមានជនណាម្នាក់បានប្រព្រឹត្តិបទល្មើសនៅលើទឹកដីប្រទេសដទៃ។

ទន្ទឹមនឹងការរីករាលដាលនៃបត្យាប័ន បច្ចុប្បន្នប្រទេសកម្ពុជាបានចុះសន្ធិសញ្ញាបត្យាប័នចំនួនប្រាំមួយសន្ធិសញ្ញា ដែលក្នុងនោះរួមមាន សន្ធិសញ្ញាបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងព្រះរាជាណាចក្រថៃ ត្រូវបានអនុម័តកាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៩។ បន្ទាប់មកសន្ធិសញ្ញាបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយសាធារណរដ្ឋប្រជាមានិតចិន ត្រូវបានអនុម័តកាលពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០០ សន្ធិសញ្ញា បត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយសាធារណរដ្ឋប្រជាមានិតឡាវ ត្រូវបានអនុម័តកាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ កិច្ចព្រមព្រៀងស្តីពី បត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ត្រូវបានអនុម័តនៅថ្ងៃទី២៦ ខែ វិច្ឆិកា ឆ្នាំ២០១០ សន្ធិសញ្ញាស្តីពីបត្យាប័នរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម ត្រូវបានអនុម័តនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤ និងអនុសញ្ញាស្តីពីបត្យាប័នរវាង រដ្ឋាភិបាលនៃប្រទេសកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥។

ម្យ៉ាងវិញទៀត ការលំបាកជាច្រើនក៏នៅតែអាចកើតមានឡើង អំឡុងពេលបង្កើតសន្ធិសញ្ញាបត្យាប័នទាំងនេះ ព្រោះរដ្ឋជាភាគីត្រូវធ្វើយ៉ាងណាឲ្យស្របតាមច្បាប់ជាធរមាន ហើយការអនុវត្តនូវបត្យាប័ននេះ ក៏ត្រូវតែគោរពតាមនីតិវិធីមួយជារួមផងដែរ។

សម្រាប់ប្រទេសកម្ពុជា ដើម្បីឲ្យបត្យាប័នមួយមានអានុភាព ត្រូវគោរពតាមលក្ខខណ្ឌ និងនីតិវិធីយ៉ាងដូចម្តេចខ្លះ?

បច្ចុប្បន្ននេះ នៅលើសាកលលោកយើង ជៀសមិនផុតពីការកើតមានបទល្មើសជាបន្តបន្ទាប់ដែលបទល្មើសអាចត្រូវបានប្រព្រឹត្តិដោយប្រជាជននៃប្រទេសនោះ ឬអាចបង្កដោយជនបរទេសដែលធ្វើដំណើរមកកាន់ប្រទេសនោះ ហើយបានរត់គេចខ្លួនទៅកាន់ប្រទេសដទៃ។ ទន្ទឹមនឹងនេះដើម្បីធានាបាននូវសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម ព្រមទាំងការអភិវឌ្ឍ

ប្រកបដោយវឌ្ឍនភាព ជាហេតុនាំឲ្យគ្រប់បណ្ដាប្រទេសទាំងឡាយមានវត្តមានរបស់បត្យាប័នកើតមានឥតឈប់ឈរ ហើយខិតខំផ្សារភ្ជាប់ បង្កើតទំនាក់ទំនងទៅវិញទៅមក។ ដោយសារតែប្រធានបទនេះ ពិតជាមានសារៈប្រយោជន៍ចំពោះប្រទេសកម្ពុជាយើង ដែលប្រជាពលរដ្ឋយើងត្រូវតែយល់ច្បាស់អំពី អ្វីទៅជាបត្យាប័ន និងអត្ថប្រយោជន៍របស់វាចំពោះប្រទេសយើង។ ទាំងនេះហើយ ជាមូលហេតុដែលធ្វើឲ្យយើងខ្ញុំបានសម្រេចចិត្តជ្រើសរើសយកប្រធានបទស្ដីពី "**បត្យាប័ន**" នេះឡើង ដើម្បីយកមកធ្វើការសិក្សា ស្រាវជ្រាវ ក្នុងគោលបំណងស្វែងយល់ពីបញ្ហានេះឲ្យកាន់តែច្បាស់ថែមទៀត និងបន្សល់ទុកឯកសារនេះសម្រាប់ចែករំលែកដល់មិត្តអ្នកអានទាំងឡាយដែលមានបំណងចង់ស្វែងយល់ពីបត្យាប័នទៀតផង ។

លើសពីនេះទៅទៀត ដើម្បីមានភាពងាយស្រួលក្នុងការសិក្សាលើប្រធានបទនេះឲ្យកាន់តែច្បាស់លាស់និងស៊ីជម្រៅ យើងខ្ញុំនឹងលើកយកត្រឹមតែចំណុចបត្យាប័នផ្អែកតាមសន្ធិសញ្ញា និងនីតិវិធីនៃការធ្វើបត្យាប័នមកបកស្រាយប៉ុណ្ណោះ ដែលការស្រាវជ្រាវលើប្រធានបទមួយនេះបានធ្វើឲ្យយើងខ្ញុំយល់កាន់តែច្បាស់ពីការធ្វើបត្យាប័នផ្អែកតាមសន្ធិសញ្ញារវាងប្រទេសកម្ពុជា និងបណ្ដាប្រទេសមួយចំនួន ក៏ដូចជានីតិវិធីផងដែរ។

បន្ថែមជាងនេះទៅទៀត ការសិក្សាស្រាវជ្រាវមួយនេះ បានធ្វើឲ្យយើងខ្ញុំបានដឹងពីទុក្ខលំបាក និងការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ក្នុងការធ្វើយ៉ាងណារឹតបន្តឹងចំណងមិត្តភាពឲ្យខានតែបានតាមរយៈ សហប្រតិបត្តិការជាមួយអន្តរជាតិ ក្នុងគោលបំណងដើម្បី បង្ក្រាប បង្កា និងអប់រំ ក៏ដូចជាបោសសំអាតបទល្មើសឆ្លងដែនជាពិសេស កុំឲ្យកើតមានឡើង និងអាចកើតមានក្នុងភាគរយតិចបំផុត។ គោលបំណង និងការខិតខំដ៏មានតម្លៃមួយនេះ គឺដើម្បីឲ្យប្រទេសកម្ពុជាយើងមានសន្តិភាព ស្ថេរភាព និងជម្រុញការអភិវឌ្ឍលើគ្រប់វិស័យប្រកបដោយនិរន្តរភាព ក្រោមការដឹកនាំដ៏ឆ្លៀសវៃរបស់រាជរដ្ឋាភិបាលបច្ចុប្បន្ន។

ចំណែកឯប្រភពឯកសារដែលជំនួយស្មារតីរបស់យើងខ្ញុំក្នុងការចងក្រងប្រធានបទមួយនេះ

គឺភាគច្រើនយើងខ្ញុំស្រាវជ្រាវមកពី តុលាការកំពូល សាលាឧទ្ធរណ៍ ក្រសួងយុត្តិធម៌ និងតាមបណ្ណាបណ្ណាល័យផ្សេងៗជាច្រើនទៀត។ ក្រៅពីឯកសារដែលមានក្នុងស្ថាប័នខាងលើ ឯកសារមួយចំនួនយើងខ្ញុំបានស្រាវជ្រាវចេញពីប្រព័ន្ធអីនធើណេតផងដែរ។ ចំពោះឯកសារសំខាន់ៗដែលពាក់ព័ន្ធនឹងប្រធានបទនេះមានដូចជា ច្បាប់ ក្រឹត្យច្បាប់ ព្រះរាជក្រម អនុក្រឹត្យ សន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀង និងឯកសារជំនួយស្មារតីរបស់សាស្ត្រាចារ្យជាច្រើនរូបផងដែរ។

បន្ទាប់ពីយើងខ្ញុំទទួលបានឯកសារគ្រប់គ្រាន់ហើយ យើងខ្ញុំធ្វើការសិក្សាស្វែងយល់ទៅលើឯកសារទាំងនោះ ហើយបែងចែកចំណាត់ថ្នាក់នៃឯកសារនីមួយៗដាក់ជាបណ្តុំ ទើបបង្កើតបានជាប្លង់សារណា និងដាក់ជូនលោកសាស្ត្រាចារ្យធ្វើការពិនិត្យ និងកែសម្រួល។ ក្រោយពេលឆ្លងកាត់ការត្រួតពិនិត្យចប់សព្វគ្រប់ យើងខ្ញុំទទួលបានប្លង់ស្ថាពរមួយដែលក្នុងនោះ បែងចែកជា ពីរជំពូក ដូចខាងក្រោមនេះ៖

**ជំពូកទី១ លក្ខខណ្ឌនៃការធ្វើបត្យាប័នតាមការព្រមព្រៀងរវាងរដ្ឋ និងរដ្ឋ**

**ផ្នែកទី១ បត្យាប័នផ្អែកតាមសន្ធិសញ្ញា**

១.១. សន្ធិសញ្ញាទ្វេភាគី

១.២. សន្ធិសញ្ញាពហុភាគី

**ផ្នែកទី២ បត្យាប័នក្នុងករណីពុំមានសន្ធិសញ្ញា**

**ជំពូកទី២ នីតិវិធីនៃការធ្វើបត្យាប័ន**

**ផ្នែកទី១ ព្រះរាជាណាចក្រកម្ពុជាជារដ្ឋដាក់សំណើ**

១.១. សំណើធ្វើបត្យាប័ន

១.២. សំណើចាប់ខ្លួនបណ្តោះអាសន្ន

១.៣. ការសម្រេចចិត្តទៅលើការស្នើសុំ

១.៤. ការអនុវត្តបត្យាប័ន

**ផ្នែកទី២ ព្រះរាជាណាចក្រកម្ពុជាជារដ្ឋទទួលសំណើ**

២.១. ការបញ្ជូនពាក្យសុំធ្វើបត្យាប័ន

២.២. ការចាប់ខ្លួន និងឃុំខ្លួនបណ្ដោះអាសន្ន

២.៣. សេចក្ដីសម្រេចពីបត្យាប័ន ។

# ជំពូកទី១

# ជំពូកទី១

# លក្ខខណ្ឌនៃការធ្វើបត្យាប័នតាមការព្រមព្រៀងរវាងរដ្ឋ និងរដ្ឋ

បត្យាប័ន គឺជាការបញ្ជូនជនល្មើសពីប្រទេសមួយទៅប្រទេសមួយទៀត ហើយបត្យាប័ននេះកើតមានឡើងបានលុះត្រាតែមានការព្រមព្រៀងរវាងរដ្ឋ និងរដ្ឋ។ ទន្ទឹមនឹងនេះ ការព្រមព្រៀងនេះគឺពឹងផ្អែកទៅលើឆន្ទៈរបស់រដ្ឋទទួលសំណើ ក្នុងការផ្ទេរជនល្មើសឲ្យទៅរដ្ឋដាក់សំណើ។ បត្យាប័នកើតមានឡើងនៅពេលដែលរដ្ឋមួយដែលជាអ្នកស្នើសុំ ហៅថារដ្ឋដាក់សំណើ ឬរដ្ឋធ្វើសំណើ បានធ្វើការស្នើសុំទៅរដ្ឋមួយផ្សេងទៀត ដើម្បីធ្វើបត្យាប័នដែលរដ្ឋនោះហៅថា រដ្ឋទទួលសំណើ។ ជាក់ស្តែង នៅពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជាយើង បានធ្វើបត្យាប័នជាមួយនឹងបណ្តាប្រទេសមួយចំនួនដូចជា ប្រទេសថៃ ប្រទេសចិន ប្រទេសឡាវ ប្រទេសកូរ៉េខាងត្បូង ប្រទេសវៀតណាម និងប្រទេសបារាំង។

ចំពោះការផ្ទេរជនល្មើសពីរដ្ឋមួយ ទៅរដ្ឋមួយ ត្រូវពឹងផ្អែកទៅលើសន្ធិសញ្ញា ក៏ប៉ុន្តែ សន្ធិសញ្ញាពុំមែនជាលក្ខខណ្ឌចាំបាច់សម្រាប់ការធ្វើបត្យាប័ននោះទេ។ វាគ្រាន់តែជាផ្នែកមួយ ដែលជួយសម្រួលដល់ការធ្វើបត្យាប័នប៉ុណ្ណោះ។ ដោយផ្អែកតាមបទបញ្ញត្តិទាក់ទងនឹងការធ្វើបត្យាប័នទាំងនេះ យើងអាចកំណត់លក្ខខណ្ឌនៃការធ្វើបត្យាប័នដូចតទៅ: **បត្យាប័នផ្អែកតាមសន្ធិសញ្ញា បត្យាប័នក្នុងករណីពុំមានសន្ធិសញ្ញា។**

## ផ្នែកទី១ បត្យាប័នផ្អែកតាមសន្ធិសញ្ញា

បច្ចុប្បន្ននេះ យើងសង្កេតឃើញថា ដើម្បីបង្កើតទំនាក់ទំនងល្អជាមួយគ្នាទៅវិញទៅមក គ្រប់បណ្តាប្រទេសទាំងអស់នៅលើសាកលលោក បាននឹងកំពុងខិតខំផ្សារភ្ជាប់ទំនាក់ទំនងគ្នា តាមរយៈការបង្កើតសន្ធិសញ្ញា។ ជាការពិតណាស់ ប្រទេសកម្ពុជាយើងបានចុះសន្ធិសញ្ញាជាច្រើនជាមួយនឹងបណ្តាប្រទេសនៅលើសាកលលោក ជាពិសេសគឺសន្ធិសញ្ញាទាក់ទងនឹងការធ្វើបត្យាប័នតែម្តង។ សន្ធិសញ្ញាទាក់ទងនឹងការធ្វើបត្យាប័ននេះ បានផ្តល់នូវភាពងាយស្រួលជាច្រើនដល់រដ្ឋជាភាគី តាម

រយៈការឲ្យរដ្ឋជាភាគីបានដឹងជាមុន នូវនីតិវិធីក្នុងការធ្វើបត្យាប័ន ព្រមទាំងដែនអនុវត្តខ្លះដែលរដ្ឋជាភាគីបានធ្វើការព្រមព្រៀងគ្នានៅក្នុងសន្ធិសញ្ញា។ យើងធ្វើការបែងចែកសន្ធិសញ្ញាជាពីរផ្សេងគ្នា។ សន្ធិសញ្ញាដែលកើតចេញពីការព្រមព្រៀងរវាងរដ្ឋពីរហៅថា សន្ធិសញ្ញាទ្វេភាគី រីឯសន្ធិសញ្ញាដែលកើតចេញពីការព្រមព្រៀងរវាងរដ្ឋច្រើនហៅថា សន្ធិសញ្ញា ពហុភាគី។

## ១.១. សន្ធិសញ្ញាទ្វេភាគី

យើងដឹងហើយថា សន្ធិសញ្ញាទ្វេភាគីគឺជាសន្ធិសញ្ញាដែលកើតឡើងតាមរយៈការព្រមព្រៀងរវាងរដ្ឋចំនួនពីរ។ ទន្ទឹមនឹងនេះ សន្ធិសញ្ញាទ្វេភាគីអាចព្រមព្រៀងគ្នាបានតាមរយៈ ការចរចាគ្នារវាងរដ្ឋ នឹងរដ្ឋ។ចំណែកឯសន្ធិសញ្ញាបត្យាប័ន គឺដូចគ្នានឹងសន្ធិសញ្ញាផ្សេងទៀតដែរ ដោយត្រូវធ្វើឡើងតាមរយៈការចរចាគ្នា ដើម្បីកំណត់នូវនីតិវិធីសមស្រប និងកំណត់នូវបទល្មើសទាំងឡាយណាដែលអនុញ្ញាតឲ្យធ្វើបត្យាប័នបាន ឬមិនបាន។

មិនតែប៉ុណ្ណោះ សន្ធិសញ្ញាទ្វេភាគី គឺជាច្បាប់ពិសេស ដែលមានលក្ខណៈច្បាស់លាស់ ហើយមានអានុភាពអនុវត្តលើច្បាប់ទូទៅ (សន្ធិសញ្ញាពហុភាគី) លើកលែងតែគូភាគីជាហត្ថលេខីនៃសន្ធិសញ្ញាព្រមព្រៀងគ្នាផ្សេងពីនេះ។ ជាទូទៅ ខ្លឹមសារនៃសន្ធិសញ្ញាបត្យាប័ន ត្រូវចែងអំពីកាតព្វកិច្ចនៃការធ្វើបត្យាប័ន បទល្មើសដែលអាចធ្វើបត្យាប័នបាន មូលហេតុដែលនាំឲ្យមានការបដិសេធក្នុងការធ្វើបត្យាប័ន នីតិវិធីនៃការធ្វើបត្យាប័ន ការចាប់ខ្លួន ការប្រគល់ខ្លួនជនដែលស្នើសុំសោហ៊ុយចំណាយក្នុងការធ្វើបត្យាប័នជាដើម។ សម្រាប់ព្រះរាជាណាចក្រកម្ពុជា គេសង្កេតឃើញមានចុះសន្ធិសញ្ញាទ្វេភាគី ទាក់ទងនឹងបត្យាប័នចំនួនប្រាំមួយ ដែលមានដូចតទៅ:

### ១.១.១. សន្ធិសញ្ញាទ្វេភាគីជាមួយប្រទេសថៃ

សន្ធិសញ្ញាបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងព្រះរាជាណាចក្រថៃ ត្រូវបានអនុម័តកាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៨។ ។ នៅក្នុងសន្ធិសញ្ញានេះ មានទាំងអស់ចំនួន ២៤ប្រការ។

### ១.១.២. សន្ធិសញ្ញាទ្វេភាគីជាមួយប្រទេសចិន

សន្ធិសញ្ញា បត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយសាធារណរដ្ឋប្រជាមានិតចិនត្រូវបាន អនុម័តកាលពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០០។ នៅក្នុងសន្ធិសញ្ញានេះ មានទាំងអស់ចំនួន ២២ប្រការ។

### ១.១.៣. សន្ធិសញ្ញាទ្វេភាគីជាមួយប្រទេសឡាវ

សន្ធិសញ្ញាបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយសាធារណរដ្ឋប្រជាមានិតឡាវ ត្រូវបានអនុម័តកាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ ។ នៅក្នុងសន្ធិសញ្ញានេះ មានទាំងអស់ចំនួន ២៤ ប្រការ។

### ១.១.៤. កិច្ចព្រមព្រៀងទ្វេភាគីជាមួយប្រទេសកូរ៉េ

កិច្ចព្រមព្រៀងស្តីពី បត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ត្រូវបានអនុម័តនៅថ្ងៃទី២៦ ខែ វិច្ឆិកា ឆ្នាំ២០១០ ។ នៅក្នុងកិច្ចព្រមព្រៀងនេះ មានទាំងអស់ចំនួន ២៣ប្រការ។

### ១.១.៥. សន្ធិសញ្ញាទ្វេភាគីជាមួយប្រទេសវៀតណាម

សន្ធិសញ្ញាស្តីពីបត្យាប័នរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម ត្រូវបាន អនុម័តនៅថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០១៤ ។ នៅក្នុងសន្ធិសញ្ញានេះ មានទាំងអស់ចំនួន ២២ មាត្រា។

### ១.១.៦. អនុសញ្ញាទ្វេភាគីជាមួយប្រទេសបារាំង

អនុសញ្ញាស្តីពីបត្យាប័នរវាងរដ្ឋាភិបាលនៃប្រទេសកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥។ នៅក្នុងអនុសញ្ញានេះ មានទាំងអស់ចំនួន ២៥ មាត្រា។

ជារួមមក សន្ធិសញ្ញា អនុសញ្ញា និងកិច្ចព្រមព្រៀងទាំងប្រាំមួយនេះ មានគោលបំណង ជម្រុញកិច្ចសហប្រតិបត្តិការដ៏មានប្រសិទ្ធិភាព រវាងប្រទេសទាំងពីរក្នុងការកំចាត់ឧក្រិដ្ឋកម្មឈរ លើមូលដ្ឋានគោរពនូវ អធិបតេយ្យភាពគ្នាទៅវិញទៅមក សមភាព និងផលប្រយោជន៍ទាំងសង ខាង។ នៅក្នុងប្រការ និងមាត្រានីមួយៗនៃសន្ធិសញ្ញា អនុសញ្ញា និងកិច្ចព្រមព្រៀងទាំងនេះ

សុទ្ធសឹងតែបានចែងអំពី កាតព្វកិច្ច , បទល្មើសដែលអាចធ្វើបត្យាប័នបាន, មូលហេតុដែលនាំឲ្យបដិសេធក្នុងការធ្វើបត្យាប័ន, នីតិវិធីនៃការធ្វើបត្យាប័ន, ការចាប់ខ្លួន, ការប្រគល់ខ្លួនជនដែលស្នើសុំ , សោហ៊ុយចំណាយក្នុងការធ្វើបត្យាប័នជាដើម។

## ១.២. សន្ធិសញ្ញាពហុភាគី

សន្ធិសញ្ញាពហុភាគី គឺជាសន្ធិសញ្ញាដែលកើតឡើងតាមរយៈការព្រមព្រៀងរវាងរដ្ឋជាច្រើន។ នាពេលបច្ចុប្បន្ននេះ មានប្រទេសជាច្រើនបានព្យាយាមធ្វើការសហការគ្នាទាំងក្នុង និងក្រៅតំបន់ ដើម្បីជួយសម្រួលនីតិវិធីក្នុងការអនុវត្តកិច្ចការនីមួយៗ ក្នុងគោលដៅបង្កើនទំនាក់ទំនងល្អជាមួយគ្នា តាមរយៈការបង្កើតឲ្យមានជាសន្ធិសញ្ញា។ ការរួមសហការគ្នា ពីរដ្ឋជាច្រើនក្នុងការបង្កើតសន្ធិសញ្ញានេះ គេឲ្យឈ្មោះថា សន្ធិសញ្ញាពហុភាគី។ សន្ធិសញ្ញានេះ បង្កើតឡើងក្នុងគោលបំណងដើម្បីរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ ជូនប្រជាពលរដ្ឋនៃរដ្ឋជាសមាជិកទាំងអស់។ ជាក់ស្តែង យើងឃើញថា សន្ធិសញ្ញាពហុភាគីទាក់ទងនឹងបត្យាប័ន មានដូចជា អនុសញ្ញាស្តីពីការលុបបំបាត់ចោលនឹងការប្រឆាំងអំពើភេរវកម្មឆ្នាំ១៩៨០ អនុសញ្ញាស្តីពីការទប់ស្កាត់ និងការដាក់ទោសរាល់បទឧក្រិដ្ឋប្រឆាំងនឹងអន្តរជាតិឆ្នាំ១៩៧៣ ដែលត្រូវបានការពារដល់រាល់ បុគ្គលទាំងឡាយ រួមទាំងភ្នាក់ងារការទូតផងដែរ។ ប៉ុន្តែព្រះរាជាណាចក្រកម្ពុជា ពុំទាន់បានចុះសន្ធិសញ្ញានឹងបត្យាប័នខាងលើនៅឡើយទេ។

## ផ្នែកទី២ បត្យាប័នក្នុងករណីពុំមានសន្ធិសញ្ញា

យើងបានដឹងរួមមកហើយថា បត្យាប័នអាចធ្វើឡើងបានតាមរយៈការព្រមព្រៀងរវាងរដ្ឋ និងរដ្ឋ ដោយសន្ធិសញ្ញាបត្យាប័ន ប៉ុន្តែក៏ពុំមានច្បាប់ ឬគោលការណ៍ណាមួយហាមឃាត់មិនឲ្យធ្វើបត្យាប័ន ដោយគ្មានសន្ធិសញ្ញាបត្យាប័ននោះទេ។ បានន័យថា ការធ្វើបត្យាប័នមិនចាំបាច់ទាមទារ

ឲ្យធ្វើឡើងតាមរយៈសន្ធិសញ្ញាបត្យាប័ននោះទេ។ ម្យ៉ាងទៀត តាមការបកស្រាយខាងលើ ការធ្វើបត្យាប័នធ្វើក្នុងគោលបំណងផ្ទេរជនល្មើស ឬទណ្ឌិត ដែលបានប្រព្រឹត្តិបទល្មើសក្នុងប្រទេសរបស់ខ្លួនឲ្យទៅប្រទេសដែលបានស្នើសុំ (ប្រទេសដាក់សំណើ) ។ ដូចនេះការធ្វើបត្យាប័ន ជាពិសេស គឺត្រូវតែពឹងផ្អែកលើឆន្ទៈជួយគ្នាទៅវិញទៅមក និងមនោសញ្ចេតនារបស់ប្រទេសជាដៃគូ ដើម្បីបង្ក្រាបបទល្មើសដែលកើតមានលើទឹកដីរបស់ខ្លួន ព្រមទាំងធានាបាននូវគុណភាពនៃការធ្វើបត្យាប័នប្រកបដោយភាតរភាព និងនិរន្តរភាព។

ប្រទេសមួយចំនួនដែលមិនមានសន្ធិសញ្ញាបត្យាប័ន ក៏បានថែងពីឆន្ទៈរបស់ខ្លួន ក្នុងការធ្វើបត្យាប័នតាមរយៈ ច្បាប់ជាតិរបស់ខ្លួន ក្នុងគោលបំណងដើម្បីជាប្រយោជន៍ដល់សហគមន៍អន្តរជាតិ ក៏ដូចជាប្រទេសដទៃទៀតដែលជាប្រទេសដាក់សំណើ។ ជាក់ស្តែង ប្រទេសឥណ្ឌូនេស៊ីអនុញ្ញាតឲ្យធ្វើបត្យាប័នបាន លុះត្រាតែការធ្វើបត្យាប័ននោះ ធ្វើឡើងក្នុងករណី បទល្មើសធ្ងន់ធ្ងរ ឬបង្កឲ្យមានមហន្តរាយដល់ប្រទេសដាក់សំណើ ក៏ដូចជាពិភពលោកទាំងមូល។ ក៏ប៉ុន្តែក៏មានប្រទេសមួយចំនួនមិនពេញចិត្ត ក្នុងការប្រគល់ជនល្មើស ឬទណ្ឌិតទៅឲ្យប្រទេសដាក់សំណើដោយស្ម័គ្រចិត្ត ដែលមានដូចជា ប្រទេសភូមា ប្រទេសស្រីលង្កា ជាដើម។

ចំណែកកម្ពុជាក៏បានទទួលស្គាល់ក្នុងករណីការធ្វើបត្យាប័ន ដោយគ្មានសន្ធិសញ្ញាបត្យាប័ននេះដែរ ដោយតាមច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម ដែលបានប្រកាសឲ្យប្រើកាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ បានកំណត់អំពី បត្យាប័នមកពីរដ្ឋបរទេស ដែលព្រះរាជាណាចក្រកម្ពុជាមិនមានសន្ធិសញ្ញាបត្យាប័នជាមួយ ដោយបានថែងថា "...រាជរដ្ឋាភិបាលកម្ពុជាអាចធ្វើសំណើរដ្ឋបរទេសសុំធ្វើបត្យាប័នលើបុគ្គលណាមួយមកព្រះរាជាណាចក្រកម្ពុជា ក្នុងករណីដែលបុគ្គលនោះ បានប្រព្រឹត្តិបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ និងក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជា មិនមានសន្ធិសញ្ញាបត្យាប័នជាមួយរដ្ឋបរទេសដែលបុគ្គលនោះមានវត្តមាន"។[១] មិនតែប៉ុណ្ណោះ ក្នុងករណីបើគ្មានសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិដែលទទួលសច្ចាប័នពីព្រះរាជាណាចក្រកម្ពុជានោះទេ

លក្ខខណ្ឌ និងនីតិវិធីនៃការធ្វើបត្យាប័នដែលស្នើសុំដោយបរទេស ឬដោយព្រះរាជាណាចក្រកម្ពុជា ចំពោះរដ្ឋបរទេស ត្រូវអនុវត្តតាមបទបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។[២] នៅពេលថ្មីៗនេះ ប្រទេសកម្ពុជា និងប្រទេសមួយចំនួនទៀតដែលជាសមាជិកអាស៊ាន បានចុះសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកព្រហ្មទណ្ឌផងដែរ។

សរុបសេចក្តីមក បត្យាប័នអាចត្រូវបានធ្វើឡើងបានតាមរយៈការបង្កើតឲ្យមានជាសន្ធិសញ្ញា ឬតាមឆន្ទៈរបស់រដ្ឋនីមួយៗ ដែលមានចែងក្នុងច្បាប់ជាតិ។ ប៉ុន្តែក្នុងករណីបត្យាប័នដោយពុំមានសន្ធិសញ្ញាបត្យាប័នទេ រដ្ឋទទួលសំណើពុំមានកាតព្វកិច្ចត្រូវតែប្រគល់ជនល្មើសឲ្យទៅរដ្ឋដាក់សំណើដើម្បីអនុវត្តទោសនោះទេ ពោលគឺផ្អែកតាមឆន្ទៈព្រមព្រៀងគ្នារបស់ប្រទេសទាំងពីរ។ នេះជាចំណោទបញ្ហាមួយ ដែលតែងកើតមានក្នុងទំនាក់ទំនងរដ្ឋ និងរដ្ឋ ដោយសាររដ្ឋទទួលសំណើត្រូវធ្វើការសម្រេចចិត្ត ថាតើត្រូវប្រគល់ជនល្មើសតាមការស្នើសុំរបស់រដ្ឋដាក់សំណើដែរឬទេ។

ម្យ៉ាងវិញទៀត ក្នុងការធ្វើបត្យាប័ន គេក៏ត្រូវពិចារណា ទៅលើ **លក្ខខណ្ឌទាក់ទងទៅនឹងបទល្មើស** ថាតើ បទល្មើសណាខ្លះដែលអាចធ្វើបត្យាប័នបាន ហើយបទល្មើសណាខ្លះទៀតដែលមិនអាចធ្វើបត្យាប័នបាន។ យោងទៅតាម ក្រមនីតិវិធីព្រហ្មទណ្ឌ បទល្មើសដែលអាចធ្វើបត្យាប័នបានមានដូចតទៅ: មាត្រា ៥៦៩ បត្យាប័នអាចធ្វើទៅបានលុះត្រាតែអំពើដែលត្រូវចោទប្រកាន់លើបុគ្គលដែលគេទាមទារនោះ ជាបទល្មើសតាមច្បាប់របស់រដ្ឋធ្វើសំណើ និងតាមច្បាប់កម្ពុជាផង ទោះបីជា អំពើនោះស្ថិតក្នុងប្រភេទបទល្មើសមិនដូចគ្នាក្តី, ឈ្មោះបទល្មើស, ការប្រើវាក្យស័ព្ទ ឬនិយមន័យ, ការប្រើបច្ចេកស័ព្ទ ឬការកំណត់លក្ខណៈបទល្មើសមិនដូចគ្នាក្តី ឬធាតុផ្សំបទល្មើសនៃច្បាប់របស់រដ្ឋធ្វើសំណើ ខុសពីធាតុផ្សំដែលកំណត់ដោយច្បាប់កម្ពុជាក៏ដោយ ប្រសិនបើពិចារណាទៅលើចំនួនសរុបនៃអំពើដែលត្រូវបានបង្ហាញដោយរដ្ឋធ្វើសំណើ គឺជាការប្រព្រឹត្តិបទល្មើសតាមបញ្ញត្តិនៃច្បាប់ជាធរមានរបស់កម្ពុជា។

ត្រង់មាត្រា ៥៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប្រសិនបើអំពើ ដែលត្រូវចោទប្រកាន់តាមច្បាប់នៃរដ្ឋផ្ញើសំណើ ជាការប៉ុនប៉ងប្រព្រឹត្តិបទល្មើស បត្យាប័នអាចធ្វើទៅបានលុះត្រាតែ ការប៉ុនប៉ងនោះ ត្រូវផ្តន្ទាទោសតាមច្បាប់កម្ពុជាដែរ។

មាត្រា ៥៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បត្យាប័នអាចធ្វើបាន លុះត្រាតែអំពើដែលត្រូវចោទប្រកាន់ទៅលើបុគ្គលដែលគេទាមទារនោះ មានកម្រិតអតិបរមានៃទោសពន្ធនាគារ យ៉ាងតិចស្មើនឹង ០២ឆ្នាំ តាមច្បាប់នៃរដ្ឋផ្ញើសំណើ។ ប៉ុន្តែបត្យាប័នក៏អាចធ្វើបានដែរ ប្រសិនបើបុគ្គលដែលគេទាមទារនោះ ត្រូវបានតុលាការនៃរដ្ឋផ្ញើសំណើ ផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិចបំផុតស្មើនឹង ០៦ខែ ហើយសេចក្តីសម្រេចនេះ បានចូលជាស្ថាពរួចហើយ ទោះបីជាទោសដែលកំណត់ដោយច្បាប់មានថិរវេលាប៉ុន្មានក៏ដោយ។

ក្នុងនោះផងដែរ ក៏មានបទល្មើសមួយចំនួន ដែលមិនអាចធ្វើបត្យាប័ន ដូចជា **បទល្មើសនយោបាយ** ទោះបីជា ប្រទេសកម្ពុជា និងបណ្តាប្រទេសដែលបានចុះសន្ធិសញ្ញាបត្យាប័នជាមួយគ្នា បានបញ្ញត្តិពីការមិនធ្វើបត្យាប័នចំពោះបទល្មើសនយោបាយក៏ពិតមែន ក៏ប៉ុន្តែ នៅក្នុងសន្ធិសញ្ញាទាំងអស់នេះ ពុំមានបញ្ញត្តិឲ្យបានច្បាស់លាស់អំពីនិយមន័យបទល្មើសនយោបាយនោះទេ។ យោងតាមមាត្រា ៥៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក៏បានចែងថា មិនត្រូវចាត់ទុកថា ជាបទល្មើសនយោបាយទេ ចំពោះអំពើហិង្សាដែលធ្វើឲ្យមានគ្រោះថ្នាក់ដល់ជីវិតដល់បូរណភាពដល់រូបកាយ ឬដល់សេរីភាពខាងបុគ្គល។ **ឧទាហរណ៍** ការប៉ុនប៉ងឃាតកម្ម ឬបំពានលើរូបកាយរបស់ប្រមុខរដ្ឋ ឬប្រមុខរដ្ឋាភិបាល។

# ជំពូកទី២

# ជំពូកទី២
# នីតិវិធីនៃការធ្វើបត្យាប័ន

បត្យាប័នត្រូវបានធ្វើឡើងដោយស្ថិតក្រោមនីតិអន្តរជាតិ ព្រោះការធ្វើបត្យាប័នត្រូវតែពាក់ព័ន្ធជាមួយរដ្ឋពីរ ឬច្រើន។ ទន្ទឹមនឹងនេះ នីតិវិធីនៃការធ្វើបត្យាប័នគឺត្រូវស្របទៅតាមច្បាប់ជាធរមានរបស់ប្រទេសដែលជាភាគីនៃបត្យាប័ន ហើយក៏ត្រូវមានការព្រមព្រៀងគ្នាជាក់លាក់ផងដែរ។

ដោយឡែក នីតិវិធីនៃការធ្វើបត្យាប័ននៅក្នុងព្រះរាជាណាចក្រកម្ពុជាវិញ គឺត្រូវអនុលោមតាមសន្ធិសញ្ញាទ្វេភាគីដែលកម្ពុជាបានចុះជាមួយ ដូចជា ប្រទេសថៃ ប្រទេសចិន ប្រទេសឡាវ ប្រទេសវៀតណាម បារាំង និងប្រទេសកូរ៉េខាងត្បូងជាដើម។ ចំពោះការធ្វើបត្យាប័នជាមួយបណ្តារដ្ឋផ្សេងៗទៀតដែលកម្ពុជាពុំបានចុះសន្ធិសញ្ញាទ្វេភាគី ឬពហុភាគីជាមួយនោះ គឺត្រូវធ្វើឡើងតាមគោលការណ៍បដិកា។ គោលការណ៍បដិកានេះមានន័យថា ជាការព្រមព្រៀងក្នុងការជួយគ្នាទៅវិញទៅមកដោយពុំមានបញ្ញត្តិចែងច្បាស់លាស់នោះទេ។

ដោយសារតែប្រទេសកម្ពុជា ជាសមាជិកនៃអង្គការសហប្រជាជាតិ នោះការអនុវត្តនីតិវិធីក្នុងករណីនេះ គឺអាចធ្វើទៅបានតាមរយៈបត្យាប័នគំរូរបស់អង្គការសហប្រជាជាតិ។ សន្ធិសញ្ញាគំរូជាសន្ធិសញ្ញាគោលមួយដែលអាចឲ្យរដ្ឋជាសមាជិកធ្វើតាមនៅពេលដែលខ្លួនមានបំណង ធ្វើសន្ធិសញ្ញាបត្យាប័ន ហើយត្រូវបានអនុម័តដោយមហាសន្និបាតរបស់អង្គការសហប្រជាជាតិតាមសេចក្តីសម្រេចលេខ ៤៥/១១៦ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩០។

ទោះបីជានីតិវិធីនៃការធ្វើបត្យាប័នត្រូវអនុលោមទៅតាមសន្ធិសញ្ញាបត្យាប័នទាំងអស់នោះក៏ពិតមែន ក៏ប៉ុន្តែសន្ធិសញ្ញាទាំងអស់នេះ ពុំបានចែងឲ្យបានច្បាស់លាស់ពីនីតិវិធីលម្អិតដែលរដ្ឋនីមួយៗត្រូវអនុវត្តនៅឡើយទេ ដូច្នេះហើយបានជាច្បាប់ជាតិរបស់ប្រទេសនីមួយៗ ក៏ត្រូវបញ្ញត្តិអំពីនីតិវិធីដែលខ្លួនត្រូវអនុវត្តដែរ។ បើក្រឡេកមកមើលច្បាប់ជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជាសព្វថ្ងៃនេះគឺប្រទេសយើងពុំមានច្បាប់ស្តីពីបត្យាប័ននោះទេ យើងគ្រាន់តែឃើញមានបញ្ញត្តិមួយ

ចំនួនដែលទាក់ទងនឹងបត្យាប័ននេះដែលមានចែងក្នុង ក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ច្បាប់ស្ដីពីការប្រឆាំងនឹងអំពើភេរវកម្ម ច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ និងច្បាប់ស្ដីការប្រឆាំងនឹងការសំអាតប្រាក់តែប៉ុណ្ណោះ។

## ផ្នែកទី១ ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋដាក់សំណើ

### ១.១. សំណើធ្វើបត្យាប័ន

ព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិក្នុងការធ្វើសំណើបត្យាប័នទៅរដ្ឋដែលជនល្មើសមួយ ឬច្រើននាក់ស្នាក់នៅបាន ក្នុងករណីដែលជនល្មើសបានប្រព្រឹត្តិបទល្មើសក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយក្រោយមកជនល្មើសបានទៅស្នាក់នៅប្រទេសដទៃទៀត ដើម្បីគេចខ្លួន និងរួចផុតពីការទទួលខុសត្រូវ ទោះជាជនល្មើសនោះមានសញ្ជាតិខ្មែរ ឬបរទេសក៏ដោយ។

ទន្ទឹមនឹងនេះ ក្រសួងយុត្តិធម៌បានបង្កើតឲ្យមានអាជ្ញាធរកណ្ដាល ដោយស្ថិតក្រោមយុត្តាធិការអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍលើវិស័យយុត្តិធម៌។[៣] អាជ្ញាធរកណ្ដាលនេះ បានដើរតួយ៉ាងសំខាន់ក្នុងការសម្របសម្រួលលើបញ្ហាបត្យាប័ន ជាពិសេសគឺជាអ្នករៀបចំ និងត្រួតពិនិត្យក្នុងការធ្វើសំណើបត្យាប័ន។ ប៉ុន្តែសេចក្ដីសម្រេចនេះ ពុំបានបញ្ជាក់អំពី នីតិវិធីនៃការបញ្ជូនជនល្មើស និងស្ថាប័នពាក់ព័ន្ធដែលត្រូវបញ្ជូនសំណើបត្យាប័ននេះទៅនោះឡើយ។

បទបញ្ញត្តិសន្ធិសញ្ញាបត្យាប័នគ្រាន់តែបញ្ជាក់ថា ការប្រាស្រ័យទាក់ទងគ្នារវាងរដ្ឋដាក់សំណើ និងរដ្ឋធ្វើសំណើ ត្រូវតែធ្វើឡើងតាមរយៈការទូត វៀរលែងតែមានបញ្ញត្តិផ្សេងចែងក្នុងកិច្ចព្រមព្រៀងនេះ។ ត្រង់ចំណុចនេះ គេចង់បញ្ជាក់ឲ្យយើងដឹងថា គ្រប់សំណើបត្យាប័នត្រូវបញ្ជូនទៅរដ្ឋមួយទៀតតាមផ្លូវទូត ប៉ុន្តែពុំបានបញ្ជាក់ថា រដ្ឋដាក់សំណើត្រូវបញ្ជូនសំណើបត្យាប័នទៅទូត

[៣] សន្ធិសញ្ញាស្ដីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន។

របស់រដ្ឋទទួលសំណើដែលតាំងនៅក្នុងប្រទេសរបស់ខ្លួន ឬតាមរយៈទូតរបស់ខ្លួនដែលតាំងនៅប្រទេសទទួលសំណើទេ។

អនុលោមតាមមាត្រា ៧ នៃកិច្ចព្រមព្រៀងស្តីពីបត្យាប័ន បានបញ្ញត្តិអំពីសំណើបត្យាប័ន និងឯកសារចាំបាច់ដែលត្រូវភ្ជាប់ជាមួយនឹងសំណើបត្យាប័ន។ សំណើបត្យាប័ន ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយត្រូវភ្ជាប់មកជាមួយនូវៈ

-ឯកសារ សេចក្តីបញ្ជាក់ ឬពត៌មានផ្សេងទៀត ដែលពិពណ៌នាអំពីអត្តសញ្ញាណ និងទីកន្លែងស្នាក់នៅប្រហាក់ប្រហែលរបស់ជនល្មើសដែលត្រូវស្នើសុំ

-សេចក្តីបញ្ជាក់លើអង្គហេតុនៃសំណុំរឿង រួមបញ្ចូលទាំងពេលវេលា និងទីកន្លែងប្រព្រឹត្តិបទល្មើស និងប្រវត្តិនីតិវិធីនៃសំណុំរឿង

-សេចក្តីបញ្ជាក់អំពីច្បាប់ ដែលពិពណ៌នាអំពីការដាក់ទណ្ឌកម្មចំពោះបទល្មើស

-សេចក្តីបញ្ជាក់អំពី ច្បាប់ដែលទាក់ទងនឹងការកំណត់ពេលនៃការចោទប្រកាន់ ឬការអនុវត្តទណ្ឌកម្មចំពោះបទល្មើស និង

-ឯកសារ សេចក្តីបញ្ជាក់ ឬពត៌មានផ្សេងទៀតដែលបញ្ជាក់នៅក្នុងកថាខណ្ឌ

ក្នុងករណីការធ្វើសំណើបត្យាប័នក្នុងគោលបំណងស្នើសុំជនល្មើស ដើម្បីធ្វើការចោទប្រកាន់នោះ គឺត្រូវភ្ជាប់មកជាមួយបត្យាប័នផងដែរនូវៈ

-សេចក្តីចម្លងនៃដីកាចាប់ខ្លួនមួយច្បាប់ ដែលចេញដោយចៅក្រមកម្ពុជា

-ពត៌មានដែលបញ្ជាក់ថា បុគ្គលដែលស្នើសុំបត្យាប័ន គឺជាបុគ្គលដែលមានដីកាចាប់ខ្លួន ឬដីកាឃុំខ្លួន និង

-សេចក្តីបញ្ជាក់អំពី ឬការខកខានដែលបានចោទប្រកាន់ បង្កើតបានជាបទល្មើស និង ភស្តុតាងគាំទ្រដែលអាចផ្តល់នូវមូលដ្ឋានត្រឹមត្រូវ គួរឲ្យសង្ស័យថា បុគ្គលដែលត្រូវធ្វើបត្យាប័ន បានប្រព្រឹត្តិបទល្មើស ដែលបត្យាប័នត្រូវបានស្នើឡើង។

ក្នុងករណីដែលការធ្វើសំណើបត្យាប័ន សំដៅទៅលើជនដែលត្រូវបានរកឃើញនូវពិរុទ្ធ សំណើបត្យាប័ន ត្រូវភ្ជាប់មកជាមួយផងដែរនូវៈ

-សេចក្តីចម្លងសាលក្រមចាប់ខ្លួន ឬឃុំខ្លួន និងសេចក្តីសម្រេចសាលក្រម តុលាការកម្ពុជា

-ពតិមានដែលបញ្ជាក់ថា បុគ្គលដែលស្នើនៅក្នុងបត្យាប័ន គឺជាបុគ្គលដែលមានពិរុទ្ធ

-សេចក្តីបញ្ជាក់ អំពីអំពើរបស់បុគ្គលនោះ ដែលត្រូវបានរកឃើញថាពិតជាមានពិរុទ្ធពិតមែន និង

-ត្រូវបញ្ជាក់ទាក់ទងនឹងមធ្យោបាយតាមផ្លូវច្បាប់ ដើម្បីឲ្យជនល្មើស ដែលត្រូវបានតុលាការផ្តន្ទាទោសតាមរយៈសាលក្រមកំបាំងមុខនោះ អាចមានសិទ្ធិក្នុងការការពារខ្លួនរបស់គេបាន ឬការជំនុំជម្រះសារជាថ្មីឡើងវិញ។

គ្រប់ឯកសារនៃសំណើបត្យាប័នទាំងអស់ដែលត្រូវបានចុះហត្ថលេខា ឬបោះត្រាជាផ្លូវការ ត្រូវតែភ្ជាប់មកជាមួយនូវ អត្ថបទបកប្រែជាភាសានៃរដ្ឋទទួលសំណើ ឬជាភាសាអង់គ្លេស។

ក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជា ដាក់សំណើទៅរដ្ឋណាមួយ ដែលកម្ពុជាពុំទាន់បាន ឬពុំបានចុះសន្ធិសញ្ញាបត្យាប័នជាមួយគ្នា នោះកម្ពុជាត្រូវអនុលោមតាមច្បាប់ជាធរមានរបស់កម្ពុជា ប៉ុន្តែនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ពុំបានបញ្ញត្តិអំពីនីតិវិធីនៃការធ្វើសំណើបត្យាប័ននោះទេ។ បើយើងក្រឡេកទៅមើលច្បាប់ស្តីពីការប្រឆាំងអំពើភេរវកម្មវិញ នៅត្រង់មាត្រា ៩៧ ក៏បានបញ្ញត្តិចែង អំពីការធ្វើសំណើបត្យាប័នដែលមានការប្រហាក់ប្រហែលគ្នាទៅនឹងកិច្ចព្រមព្រៀងស្តីពីបត្យាប័នផងដែរ។

## ១.២. សំណើចាប់ខ្លួនបណ្តោះអាសន្ន

ក្នុងករណីចាំបាច់ ប្រទេសកម្ពុជា អាចមានសិទ្ធិស្នើសុំទៅរដ្ឋទទួលសំណើ ដើម្បីធ្វើការចាប់ខ្លួនបណ្តោះអាសន្នចំពោះជនល្មើស ដែលត្រូវបានស្នើសុំ ក្នុងការបញ្ជូនខ្លួនមកកម្ពុជា តាមរយៈការធ្វើបត្យាប័ន។ សំណើទាំងនេះ ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្រោមទិដ្ឋភាពការទូត ឬតាមរយៈអង្គការនគរបាលព្រហ្មទណ្ឌអន្តរជាតិ ដែលគេស្គាល់ថាជា ***អាំងទែប៉ូល*** ។

សំណើចាប់ខ្លួនបណ្តោះអាសន្នខាងលើនេះ ត្រូវភ្ជាប់មកជាមួយនូវ ៖

- ពិពណ៌នាអំពីជនដែលត្រូវស្នើសុំ និងពត៌មានអំពីសញ្ជាតិនៃបុគ្គលនោះ
- សេចក្តីបញ្ជាក់នៃទីតាំងដែលជននោះស្ថិតនៅ (ប្រសិនបើដឹង)
- សេចក្តីបញ្ជាក់សង្ខេបអំពី អង្គហេតុនៃសំណុំរឿង (បើអាចធ្វើបាន)
- ការពិពណ៌នាអំពីអង្គច្បាប់
- សេចក្តីបញ្ជាក់សាលក្រមចាប់ខ្លួន ឬសាលក្រមនៃការផ្តន្ទាទោស
- សេចក្តីបញ្ជាក់អំពីបត្យាប័ន លើជនដែលត្រូវស្នើសុំ និងត្រូវបញ្ជូនតាមក្រោយ។

សំណើឲ្យធ្វើការចាប់ខ្លួនបណ្តោះអាសន្ន អាចធ្វើឡើងមុនពេលធ្វើសំណើបត្យាប័នបានក៏ពិតមែន ប៉ុន្តែរដ្ឋដាក់សំណើ ត្រូវធ្វើសំណើបត្យាប័នជាផ្លូវការ និងឯកសារសំអាងនានា ដូចដែលបានកំណត់ខាងលើ ក្នុងរយៈ ៦០ថ្ងៃ បន្ទាប់ពីពេលចាប់ខ្លួនជននោះ។

## ១.៣. ការសម្រេចចិត្តទៅលើការស្នើសុំ

ដើម្បីធ្វើការសម្រេចសេចក្តីទៅលើសំណើបត្យាប័ន របស់ព្រះរាជាណាចក្រកម្ពុជា រដ្ឋទទួលសំណើនឹងធ្វើការត្រួតពិនិត្យ ដោយយោងទៅលើសន្ធិសញ្ញាទ្វេភាគី ឬសន្ធិសញ្ញាពហុភាគី និងនីតិវិធីរបស់ប្រទេសគេជាមុនសិន។

ក្នុងករណីដែលប្រទេសជាច្រើនដើរតួជារដ្ឋដាក់សំណើក្នុងការធ្វើបត្យាប័នទៅឲ្យរដ្ឋទទួលសំណើ ដើម្បីបញ្ជូនជនល្មើសតែម្នាក់ នោះរដ្ឋទទួលសំណើ មានសិទ្ធិសម្រេចថា គួរផ្តល់បត្យាប័នជូនរដ្ឋដាក់សំណើមួយណាមុន ពោលគឺផ្អែកទៅលើច្បាប់ ក៏ដូចជាសន្ធិសញ្ញាអន្តរជាតិ។

មិនតែប៉ុណ្ណោះ បើរដ្ឋទទួលសំណើយល់ថា ប្រទេសកម្ពុជាផ្តល់អង្គហេតុ សេចក្តីបញ្ជាក់ ឬពត៌មាននៅមិនទាន់គ្រប់គ្រាន់នៅឡើយនោះ រដ្ឋទទួលសំណើ មានសិទ្ធិស្នើសុំដល់រដ្ឋដាក់សំណើឲ្យផ្តល់ពត៌មានបន្ថែមទៅលើ ចំណុចណាដែលខ្វះខាត និងកំណត់ថិរវេលាមួយសមស្របដើម្បីឲ្យរដ្ឋដាក់សំណើបញ្ជូនឯកសារនោះ។ ប៉ុន្តែបើរដ្ឋដាក់សំណើមិនផ្តល់ឯកសារបន្ថែមតាមការស្នើសុំក្នុងរយៈពេលនៃការកំណត់ គឺបានន័យថាកម្ពុជាលះបង់នូវសំណើបត្យាប័ននេះចោល។ ទោះបីជាយ៉ាងណាក៏ដោយ ក៏កម្ពុជានៅតែមានសិទ្ធិក្នុងការស្នើសុំបត្យាប័នក្នុងរឿងដដែលសារជាថ្មីម្តងទៀតបាន។

ទោះបីជារដ្ឋទទួលសំណើសម្រេចយល់ព្រម ឬបដិសេធនូវសំណើបត្យាប័នរបស់កម្ពុជាក៏ដោយ ក៏រដ្ឋទទួលសំណើត្រូវតែបញ្ជូននូវការសម្រេចចិត្តមួយនេះ ឲ្យមកកម្ពុជាវិញ តាមរយៈផ្លូវទូតផងដែរ។ បើរដ្ឋទទួលសំណើមិនយល់ស្រប ក្នុងការផ្តល់បត្យាប័នទេនោះ រដ្ឋនេះត្រូវតែមានហេតុផលច្បាស់លាស់ណាមួយផ្តល់ជូនកម្ពុជាវិញ។ ផ្ទុយទៅវិញ បើរដ្ឋទទួលសំណើយល់ព្រមជនដែលត្រូវបានស្នើសុំនោះ បត្យាប័ននឹងអាចត្រូវបានអនុវត្តតែម្តង។

ពិសេសជាងនេះទៅទៀត កាលបើជនដែលត្រូវបានគេកំពុងតែស្នើសុំដើម្បីបញ្ជូនរូបគេចូលមាតុភូមិវិញនោះ ដោយសាមីខ្លួនគេផ្ទាល់បានយល់ដឹងយ៉ាងច្បាស់ពីរបៀប នៃការការពារខ្លួន ក៏ដូចជាដំណើរការ នៃការធ្វើបត្យាប័នរួចរាល់ហើយបន្ទាប់ពីមានការពន្យល់យ៉ាងក្បោះក្បាយពីអាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋទទួលសំណើហើយនោះ វាជាមធ្យោបាយមួយដ៏ងាយស្រួល ដោយរដ្ឋទទួលសំណើ គ្រាន់តែផ្តល់បត្យាប័នមកប្រទេសកម្ពុជាវិញ ដោយមិនត្រូវការប្រើប្រាស់នូវនីតិវិធីជាផ្លូវការអ្វីមួយទេ។

## ១.៤. ការអនុវត្តបត្យាប័ន

ដើម្បីឲ្យការអនុវត្តបត្យាប័នមួយមានដំណើរការឆ្ពោះទៅមុខយ៉ាងរលូន និងមានគុណភាពប្រកបដោយប្រសិទ្ធិភាពខ្ពស់នោះ លុះត្រាណាតែមានការព្រមព្រៀងគ្នាយ៉ាងពិតប្រាកដរវាងព្រះរាជាណាចក្រកម្ពុជា ដែលជារដ្ឋដាក់សំណើ ជាមួយនឹងរដ្ឋទទួលសំណើ។ មាត្រា ១៩ នៃកិច្ចព្រមព្រៀងស្តីពីបត្យាប័នបានកំណត់ថា ភាគីទទួលសំណើត្រូវចេញសោហ៊ុយនៃដំណើរការនីតិវិធីណាមួយ ដែលស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួន ដែលកើតឡើងពីសំណើធ្វើបត្យាប័ន។ ចំណែកភាគីទទួលសំណើត្រូវចេញសោហ៊ុយដែលកើតឡើងនៅក្នុងដែនដីរបស់ខ្លួន ទាក់ទងនឹងការចាប់ខ្លួន និងការឃុំខ្លួននៃជនដែលស្នើសុំបត្យាប័ន ឬការដកហូត និងការប្រគល់ទ្រព្យសម្បត្តិ ។ ភាគីដាក់សំណើត្រូវចេញសោហ៊ុយ ដែលកើតឡើងពីការដឹកជញ្ជូនបុគ្គលដែលបត្យាប័នត្រូវផ្តល់ជូនពីទឹកដីនៃភាគីទទួលសំណើ រួមទាំងសោហ៊ុយធ្វើដំណើរឆ្លងកាត់។

ការអនុវត្តបត្យាប័ន ត្រូវធ្វើឡើងតាមវិធីពីរយ៉ាងគឺះ

### ១. ការប្រគល់ជនដែលត្រូវស្នើសុំ:

មុននឹងឆ្ពោះទៅដល់ការបញ្ជូនខ្លួនជនដែលត្រូវស្នើសុំនោះទៅឲ្យរដ្ឋដាក់សំណើ លុះណាតែរដ្ឋទទួលសំណើ បានឈានទៅដល់ការចាប់ខ្លួនជននោះជាមុនសិន។ បន្ទាប់មកភាគីរដ្ឋទាំងសងខាងនឹងចរចាគ្នា ពីពេលវេលាមួយដែលសមគួរក្នុងការប្រគល់ស្របពេលជាមួយនឹងការទទួលយកជនដែលត្រូវបានគេធ្វើបត្យាប័ននេះតែម្តង។

បើអនុលោមទៅតាមកិច្ចព្រមព្រៀងស្តីពីបត្យាប័នដែលបានចែងក្នុង មាត្រា១២ បានលើកឡើងបញ្ជាក់ថា:

១. ប្រសិនបើបត្យាប័ន ត្រូវបានផ្តល់ឲ្យភាគីទទួលសំណើ និងភាគីដាក់សំណើ ត្រូវសម្រេចអំពីការអនុវត្តបត្យាប័នតាមរយៈការពិគ្រោះយោបល់គ្នា។ សម្រាប់គោលបំណងនេះ ភាគីទទួលសំណើត្រូវជូនពត៌មានដល់ភាគីដាក់សំណើអំពី រយៈពេលជនដែលត្រូវស្នើសុំនោះត្រូវបានចាប់ឃុំឃាំងមុនពេលប្រគល់ខ្លួន។

២. ភាគីដាក់សំណើត្រូវចាត់ទុកថា បានបោះបង់សំណើបត្យាប័ន ប្រសិនបើភាគីនេះពុំទទួលយកជនដែលត្រូវបានស្នើសុំក្នុងរយៈពេល ១៥ថ្ងៃ ក្រោយពីថ្ងៃដែលការអនុវត្តបត្យាប័នបានព្រមព្រៀងគ្នារួចហើយ។ ភាគីទទួលសំណើត្រូវដោះលែងជននោះឲ្យមានសេរីភាពជាបន្ទាន់ ហើយអាចបដិសេធការធ្វើបត្យាប័នចំពោះបទល្មើសដដែលនេះ។

៣.ប្រសិនបើភាគីណាមួយខកខានពុំបានប្រគល់ ឬទទួលយកជនដែលត្រូវស្នើសុំក្នុងថិរវេលាដែលបានព្រមព្រៀងគ្នា ដោយសារករណីប្រធានសក្តិ ភាគីម្ខាងទៀតត្រូវតែទទួលបាននូវ ពត៌មានអំពីបញ្ហានេះ។ គូភាគីត្រូវសម្រេចចិត្តជាថ្មីម្តងទៀត តាមការពិគ្រោះយោបល់គ្នា អំពីការអនុវត្តបត្យាប័ន។

ចំណែកឯរដ្ឋទទួលសំណើ ក៏អាចមានសិទ្ធិក្នុងការពន្យាពេល ដើម្បីបញ្ជូនជនដែលត្រូវបានស្នើសុំមកកម្ពុជាវិញផងដែរ ពោលគឺក្នុងអំឡុងពេលដែលជននោះកំពុងតែស្ថិតនៅក្រោមនីតិវិធីជំនុំជម្រះក្តី ឬកំពុងតែទទួលទោសចំពោះការផ្តន្ទាទោសជាប់ពន្ធនាគារ នៅក្នុងរដ្ឋទទួលសំណើនេះតែម្តង គឺដោយសារតែជននោះបានប្រព្រឹត្តិបទល្មើសថ្មីមួយនៅក្នុងរដ្ឋទទួលសំណើ ដែលវាជាបទល្មើសមួយផ្សេងពីបទល្មើសដែលជាកម្មវត្ថុនៃការធ្វើបត្យាប័ន។ ដូច្នេះជននេះត្រូវទទួលរងនូវការជំនុំជម្រះក្តី ឬទទួលទោសទៅតាមការសម្រេចចិត្តរបស់តុលាការជាមុនសិន មុននឹងរដ្ឋទទួលសំណើត្រូវបញ្ជូនជននោះមកកម្ពុជាវិញ។ ដោយសារតែមូលហេតុនេះហើយ រដ្ឋទទួលសំណើចាំបាច់ត្រូវតែផ្តល់ដំណឹងជូនដល់ប្រទេសកម្ពុជាពីការស្នើសុំពន្យាពេលនេះ។

មិនតែប៉ុណ្ណោះ ការប្រគល់ជនដែលត្រូវស្នើសុំ ទៅរដ្ឋដែលស្នើសុំ ក៏អាចធ្វើឡើងបានជាបណ្តោះអាសន្នផងដែរ។ ប្រសិនបើច្បាប់របស់ខ្លួនអនុញ្ញាតនៅពេលដែលជនណាម្នាក់ត្រូវបានរកឃើញថាអាចធ្វើបត្យាប័នបាន ភាគីទទួលសំណើ អាចប្រគល់ជនដែលត្រូវស្នើសុំជាបណ្តោះអាសន្នមកកម្ពុជា ដើម្បីធ្វើការចោទប្រកាន់ស្របទៅតាមលក្ខខណ្ឌដែលបានកំណត់រវាងប្រទេសកម្ពុជា និងរដ្ឋទទួលសំណើ។ ជនណាម្នាក់ដែលត្រូវបានប្រគល់ទៅភាគីរដ្ឋទទួលសំណើ បន្ទាប់ពីការប្រគល់ខ្លួនបណ្តោះអាសន្ន អាចត្រូវប្រគល់ខ្លួនជាស្ថាពរទៅភាគីរដ្ឋដាក់សំណើផងដែរ ដែលកំណត់តាមរយៈសាលក្រម ឬសាលដីកាផ្អែកតាមការព្រមព្រៀងគ្នា។[៤]

## ២. ការប្រគល់ទ្រព្យសម្បត្តិ:

ក្នុងករណីដែលច្បាប់របស់ខ្លួនអនុញ្ញាតឲ្យ និងមានការស្នើសុំពីភាគីរដ្ឋដាក់សំណើផងដែរនោះ ភាគីទទួលសំណើអាចមានសិទ្ធិក្នុងការរឹបអូសទ្រព្យសម្បត្តិរបស់ជនល្មើស។ ក្រោយពីការផ្តល់បត្យាប័នរួច រដ្ឋទទួលសំណើត្រូវប្រគល់ទ្រព្យសម្បត្តិ ដែលអាចតម្រូវឲ្យធ្វើជាភស្តុតាង ឬបង្ហាញនូវអ្វីដែលធ្លាប់ទទួលបានមកពីលទ្ធផលនៃបទល្មើស។[៥] ទ្រព្យសម្បត្តិទាំងនេះ ត្រូវតែប្រគល់ជូនរដ្ឋដាក់សំណើជាដាច់ខាត ទោះបីជាការធ្វើបត្យាប័ននោះមិនអាចអនុវត្តទៅបានដោយសារមូលហេតុមកពីមរណភាព ការបាត់ខ្លួន ឬការគេចខ្លួនរបស់ជនល្មើសក៏ដោយ។

ប្រសិនបើការរឹបអូសទ្រព្យសម្បត្តិខាងលើនេះធ្វើឡើងក្នុងទឹកដីនៃរដ្ឋទទួលសំណើ ភាគីទទួលសំណើអាចធ្វើការរក្សាទុកជាបណ្តោះអាសន្នបាន ឬបញ្ជូនមករដ្ឋដាក់សំណើដើម្បីដំណើរការនីតិវិធីទាក់ទងនឹងទ្រព្យនោះ ហើយត្រូវប្រគល់ទៅរដ្ឋទទួលសំណើវិញ។ សិទ្ធិទាំងឡាយណាដែលភាគីណាមួយ ឬបុគ្គលណាមួយ អាចទទួលបានទ្រព្យសម្បត្តិនោះត្រូវរក្សាទុក។ នៅពេលដែលសិទ្ធិទាំងនោះនៅមាននៅឡើយ ទ្រព្យសម្បត្តិទាំងនោះ ត្រូវបញ្ជូនទៅរដ្ឋទទួលសំណើតាម

---

[៤] មាត្រា១៣ កថាខណ្ឌទី២ នៃកិច្ចព្រមព្រៀងស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណៈរដ្ឋកូរ៉េ ។
[៥] មាត្រា១៦ នៃកិច្ចព្រមព្រៀងស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណៈរដ្ឋកូរ៉េ ។

សំណូមពររបស់ខ្លួន ដោយគ្មានបន្ទុកពន្ធអាករឲ្យបានឆាប់បំផុតតាមលទ្ធភាពដែលអាចធ្វើទៅបាន បន្ទាប់ពីបញ្ចប់ការជំនុំជម្រះក្តី។

## ផ្នែកទី២ ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋទទួលសំណើ

ក្នុងករណីដែលប្រទេសណាមួយបានដាក់សំណើបត្យាប័នមកកាន់ប្រទេសកម្ពុជាឲ្យប្រគល់ជនល្មើសដែលស្នើសុំឲ្យទៅប្រទេសដាក់សំណើវិញ នោះប្រទេសកម្ពុជា នឹងក្លាយជាប្រទេសទទួលសំណើ។ ទន្ទឹមនឹងនេះផងដែរ នីតិវិធីនៃការធ្វើបត្យាប័នក្នុងករណីខាងលើ ក៏មិនខុសពីករណីដែលប្រទេសកម្ពុជាជារដ្ឋដាក់សំណើដែរ គ្រាន់តែប្តូរទិសដៅប៉ុណ្ណោះ។ ចំណែកការធ្វើបត្យាប័នរបស់រដ្ឋបរទេស មកលើប្រទេសកម្ពុជាវិញ គឺរដ្ឋនោះត្រូវតែអនុលោមទៅតាមច្បាប់របស់រដ្ឋគេផ្ទាល់ ហើយជាទូទៅត្រូវបញ្ជូនមកប្រទេសកម្ពុជាតាមរយៈទូតបរទេសប្រចាំនៅកម្ពុជា ហើយត្រូវបញ្ជូនតាមរយៈរដ្ឋមន្ត្រីក្រសួងការបរទេស បន្ទាប់មកទើបរដ្ឋមន្ត្រីក្រសួងការបរទេស ចាត់ចែងកិច្ចការ បន្តនីតិវិធីតាមច្បាប់នៃប្រទេសកម្ពុជា។

ចំពោះនីតិវិធីដែលប្រទេសកម្ពុជា ត្រូវអនុវត្តក្នុងរឿងបត្យាប័ន ប្រទេសកម្ពុជាពុំទាន់មានច្បាប់ដាច់ដោយឡែកណាមួយស្តីពីនីតិវិធីនៃការធ្វើបត្យាប័ននៅឡើយទេ។ ទោះជាយ៉ាងណាក៏ដោយ គេសង្កេតឃើញមានច្បាប់មួយចំនួនដែលបានចែងទាក់ទិនទៅនឹងការធ្វើបត្យាប័ននេះដូចជា **ក្រមនីតិវិធីព្រហ្មទណ្ឌ** និង **ច្បាប់ស្តីពីការប្រឆាំងនឹងអំពើភេរវកម្ម**។ ដោយសារតែ នីតិវិធីក្នុងករណីដែលប្រទេសកម្ពុជា ជារដ្ឋទទួលសំណើ គឺមិនខុសប្លែកពីករណីដែលប្រទេសកម្ពុជា ជារដ្ឋដាក់សំណើនោះទេ ករណីនេះ យើងសូមលើកយកតែករណីដែលមានបញ្ញត្តិប្លែកពីករណីដែលប្រទេសកម្ពុជាធ្វើជារដ្ឋដាក់សំណើប៉ុណ្ណោះ។

## ២.១. ការបញ្ជូនពាក្យសុំធ្វើបត្យាប័ន

ដូចដែលធ្លាប់បានបញ្ជាក់ខាងលើរួចមកហើយថា ការបញ្ជូនបត្យាប័នមកប្រទេសកម្ពុជា ត្រូវធ្វើឡើងតាមរយៈទូតបរទេសដែលប្រចាំនៅកម្ពុជា តាមការបញ្ជូនបត្យាប័នមករដ្ឋមន្ត្រីក្រសួងការបរទេស។

បន្ទាប់មកទើប រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា បញ្ជូនពាក្យស្នើសុំឲ្យធ្វើបត្យាប័ន និងលិខិតបញ្ជាក់ភស្តុតាងទៅកាន់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ ក្នុងដំណាក់កាលនេះ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ផ្ទៀងផ្ទាត់មើលនិយ័តភាពនៃពាក្យសុំ ហើយបញ្ជូនពាក្យនោះ ទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដែលមានទីតាំងនៅរាជធានីភ្នំពេញ។[៦]

មិនតែប៉ុណ្ណោះ ការបញ្ជាក់ថាត្រឹមត្រូវចំពោះពាក្យសុំធ្វើបត្យាប័ន កាលណាពាក្យសុំនោះត្រូវមានលិខិតបញ្ជាក់ភស្តុតាងអមជាមួយ ដែលលិខិតបញ្ជាក់ភស្តុតាងនោះត្រូវមានៈ

-ឯកសារដែលមានលក្ខណៈគ្រប់គ្រាន់ ក្នុងការកំណត់អត្តសញ្ញាណបុគ្គលដែលគេទាមទារ

-របាយការណ៍អំពីអង្គហេតុដែលត្រូវចោទប្រកាន់ លើបុគ្គលដែលគេទាមទារ

-អត្ថបទច្បាប់ដែលអនុវត្ត ទៅលើអំពើល្មើស និងទោសដែលត្រូវទទួលរង

-លិខិតចម្លងនៃសេចក្តីសម្រេចផ្តន្ទាទោសប្រសិនបើមាន។

ឯកសារទាំងអស់ ត្រូវចុះហត្ថលេខា បោះត្រាជាផ្លូវការ និងបិទស្រោម ហើយប្រសិនបើមិនមែនជាភាសាខ្មែរ បារាំង ឬអង់គ្លេស ត្រូវតែភ្ជាប់មកជាមួយនូវឯកសារបកប្រែជាភាសាមួយនៃភាសាទាំងបីនេះ ដោយមានសេចក្តីបញ្ជាក់ផង។[៧]

---

[៦] មាត្រា ៥៨០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧។

[៧] មាត្រា ៥៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧។

## ២.២. ការចាប់ខ្លួន និងការឃុំខ្លួនបណ្ដោះអាសន្ន

ក្នុងករណីការចាប់ខ្លួន និងការឃុំខ្លួនបណ្ដោះអាសន្នដែលធ្វើឡើងដោយរដ្ឋដែលមានសន្ធិសញ្ញាបត្យាប័នជាមួយនឹងប្រទេសកម្ពុជា នោះនីតិវិធីនៃការចាប់ខ្លួន ត្រូវអនុលោមតាមបញ្ញត្តិនៃសន្ធិសញ្ញានោះ។ ផ្ទុយទៅវិញ បើរដ្ឋដែលគ្មានសន្ធិសញ្ញាបត្យាប័នជាមួយកម្ពុជាជាអ្នកធ្វើការស្នើសុំ នោះនីតិវិធីត្រូវអនុលោមតាមក្រមនីតិវធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាវិញ។ ប៉ុន្តែបើបទល្មើសដែលជាកម្មវត្ថុនៃការធ្វើបត្យាប័ន ព្រមទាំងការចាប់ខ្លួន និងឃុំខ្លួន ដែលត្រូវបានចែងដោយច្បាប់ពិសេសណាមួយ ដែលតាមរយៈច្បាប់នោះ ក៏បានបញ្ញត្តិអំពីការធ្វើបត្យាប័នដែរនោះដូចជាច្បាប់ស្ដីពីការប្រឆាំងអំពើភេរវកម្មជាដើមនោះ យើងត្រូវអនុវត្តនីតិវិធីនៃការចាប់ខ្លួន និងឃុំខ្លួនតាមបញ្ញត្តិពិសេសនោះតែម្ដង។

ម្យ៉ាងទៀត រដ្ឋដែលធ្វើសំណើឲ្យធ្វើបត្យាប័ន អាចសុំឲ្យចាប់ខ្លួនបណ្ដោះអាសន្នបាននូវបុគ្គលដែលគេទាមទារ។ ក្នុងករណីបន្ទាន់ ពាក្យសុំឲ្យចាប់ខ្លួនបណ្ដោះអាសន្ន អាចធ្វើមុនពាក្យសុំឲ្យធ្វើបត្យាប័នដែលមានចែងក្នុងមាត្រា ៥៧៩ (ការបញ្ជាក់ថាត្រឹមត្រូវចំពោះពាក្យសុំធ្វើបត្យាប័ន) នៃក្រមនីតិវិធីព្រហ្មទណ្ឌបាន។ ពាក្យសុំឲ្យចាប់ខ្លួនបណ្ដោះអាសន្ន ដែលមានគោលដៅរារាំងដល់ការគេចខ្លួនបុគ្គលដែលគេទាមទារ មិនតម្រូវឲ្យគោរពទម្រង់បែបបទដោយឡែកឡើយ។ បុគ្គលដែលត្រូវស្ថិតក្រោមនីតិវិធីនៃការចាប់ខ្លួនបណ្ដោះអាសន្ន ត្រូវតែបានដោះលែងឲ្យមានសេរីភាពឡើងវិញដោយឯកឯង ប្រសិនបើរាជរដ្ឋាភិបាលពុំបានទទួលឯកសារទាំងឡាយដូចដែលមានចែងក្នុងមាត្រា ៥៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងរយៈពេល ០២(ពីរ) ខែ គិតពីថ្ងៃចាប់ខ្លួនទេនោះ។[៨]

**ឧទាហរណ៍:** យោងតាមសំណុំរឿងព្រហ្មទណ្ឌ(**បត្យាប័ន**)លេខ: ៣២ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៦ របស់តុលាការកំពូល រដ្ឋាភិបាលនៃប្រទេសរុស្សី(រដ្ឋធ្វើសំណើ) បានដាក់សំណើ

---

[៨] មាត្រា ៥៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

បត្យាប័នមកកាន់ប្រទេសកម្ពុជាក្នុងការទាមទារ ជនជាតិរុស្សីម្នាក់ ដែលបានប្រព្រឹត្តិបទល្មើសបោកប្រាក់ក្រុមហ៊ុននៅសហព័ន្ធរុស្សីនៅចន្លោះឆ្នាំ២០០៧-២០០៨ និងរត់មកលាក់ខ្លួននៅកម្ពុជា ដោយហេតុថាប្រទេសកម្ពុជា និងប្រទេសរុស្សីនៅមិនទាន់មានកិច្ចព្រមព្រៀងបត្យាប័ននឹងគ្នានៅឡើយ ដូច្នេះតុលាការអាចយកបញ្ញត្តិនៃមាត្រា ៥៦៧ វាក្យខណ្ឌ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌមកអនុវត្ត។ ករណីនេះ ត្រូវបានមហាអយ្យការនៃសាលាឧទ្ធរណ៍ធ្វើការសន្និដ្ឋានថា ចំពោះសភាស៊ើបសួរគួរសម្រេចផ្តល់យោបល់យល់ព្រមឲ្យធ្វើបត្យាប័នលើបុគ្គលនោះតាមការស្នើសុំ ដោយគេយល់ឃើញថា ពាក្យសុំធ្វើបត្យាប័ននោះធ្វើឡើងដោយអនុលោមតាមច្បាប់ត្រង់មាត្រា ៥៧៩ និងមាត្រា៥៨០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងយល់ឃើញថា បុគ្គលនោះពិតជាបានប្រព្រិត្តិបទល្មើសបោកប្រាក់នៅរុស្សី ហើយរត់មកលាក់ខ្លួននៅកម្ពុជារយៈពេល ០៥ឆ្នាំ មកហើយ ទើបសមត្ថកិច្ចចាប់ខ្លួនក្នុងឆ្នាំ២០១៦នៅខេត្តព្រះសីហនុ។

មិនតែប៉ុណ្ណោះ ដោយសារតែតុលាការយល់ឃើញថា អំពើប្រព្រិត្តិរបស់បុគ្គល ជនជាតិរុស្សី បានល្មើសច្បាប់ព្រហ្មទណ្ឌរបស់សហព័ន្ធរុស្សី ក៏ជាអំពើល្មើសច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជាដូចគ្នា ដូចដែលមានចែងក្នុងមាត្រា ៥៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ទើបគេបានផ្តល់ការយល់ព្រមឲ្យធ្វើបត្យាប័នលើពិរុទ្ធជនខាងលើបាន។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចចេញបញ្ជាឲ្យចាប់ខ្លួន និងឃុំខ្លួន បុគ្គលដែលគេទាមទារ។ បញ្ជានេះមានចុះនិទ្ទេសដូចតទៅ:

-អត្តសញ្ញាណបុគ្គលដែលគេទាមទារ

-ការយោងនៃពាក្យសុំឲ្យចាប់ខ្លួនជាបណ្តោះអាសន្នរបស់រដ្ឋបរទេស

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញបញ្ជានេះ។

បញ្ជានេះត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយអគ្គព្រះរាជអាជ្ញា និងមានបោះត្រាផងដែរ។ បញ្ជាឲ្យចាប់ និងឃុំខ្លួននេះ មានអានុភាពអនុវត្តនៅលើដែនដីកម្ពុជាទាំងមូល។[៩]

បើយោងទៅតាម មាត្រា ១០១ នៃច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម ក៏បានបញ្ញត្តិទាក់ទងនឹងការចាប់ខ្លួន ការឃាត់ខ្លួន និងការឃុំខ្លួនបណ្តោះអាសន្នក្នុងរឿងបត្យាប័នផងដែរដោយបានបញ្ញត្តិថា:

១.មាត្រានេះត្រូវអនុវត្ត ប្រសិនបើ៖

ក.អាជ្ញាធរទទួលបន្ទុកចោទប្រកាន់ ទទួលបន្ទុកសំណើពីរដ្ឋបរទេសណាមួយ ដោយផ្ទាល់ ឬតាមរយៈការសម្របសម្រួលនៃអង្គភាពនគរបាលព្រហ្មទណ្ឌអន្តរជាតិ សុំឲ្យធ្វើការចាប់ខ្លួនបុគ្គលណាម្នាក់ជាបណ្តោះអាសន្ន ចំពោះបទល្មើស តាមបញ្ញត្តិនៃច្បាប់នេះ ហើយមានករណីណាមួយនៃករណីខាងក្រោមនេះ៖

ក.១. ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋនៃសន្ធិសញ្ញាបត្យាប័នជាមួយរដ្ឋដែលស្នើសុំជំនួយ ឬ

ក.២. ទាំងព្រះរាជាណាចក្រកម្ពុជា ទាំងរដ្ឋបរទេសនោះ គឺជាភាគីនៃអនុសញ្ញា ឬពិធីសារដែលភ្ជាប់មកជាឧបសម្ព័ន្ធ ១ នៃច្បាប់នេះ និងអនុសញ្ញា ឬពិធីសារនោះ ចែងថាវាអាចផ្តល់មូលដ្ឋានច្បាប់សម្រាប់បត្យាប័នឬ

ក.៣. រដ្ឋធ្វើសំណើផ្តល់ការសន្យាថា នឹងអនុវត្តតាមសំណើដូចគ្នាពីព្រះរាជាណាចក្រកម្ពុជា

ខ. រដ្ឋធ្វើសំណើ សន្យាផ្ញើជូនព្រះរាជាណាចក្រកម្ពុជា នូវសំណើសុំធ្វើបត្យាប័នចំពោះបុគ្គលនោះ

២. អាជ្ញាធរទទួលបន្ទុកចោទប្រកាន់អាចចេញដីកាចាប់ខ្លួនប្រសិនបើពិនិត្យឃើញថា:

ក. បុគ្គលនោះមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយ

[៩] មាត្រា ៥៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

ខ. ទោះបីជា:

ខ១. តុលាការ ឬអាជ្ញាធរនៅក្នុងរដ្ឋធ្វើសំណើបានចេញដីកា ឬបញ្ជាដែលមានលក្ខណៈដូចគ្នា ដើម្បីចាប់ខ្លួនបុគ្គលនោះ ចំពោះបទល្មើសទាក់ទងនឹងដីកាចាប់ខ្លួនបណ្តោះអាសន្ន ដែលត្រូវបានសុំនោះ ឬ

ខ២. បុគ្គលនោះបានសម្រេចឲ្យជាប់ទោសចំពោះបទល្មើសនោះនៅក្នុងរដ្ឋធ្វើសំណើ

៣. ផ្អែកតាមកថាខណ្ឌទី៤ ខាងក្រោមនេះ បុគ្គលដែលត្រូវចាប់ខ្លួន និងឃុំខ្លួនតាមដីកា នឹងត្រូវឃុំខ្លួនតាមផ្លូវច្បាប់ រហូតទាល់តែរដ្ឋធ្វើសំណើ ស្នើសុំឲ្យរាជរដ្ឋាភិបាលកម្ពុជា (រដ្ឋទទួលសំណើ) ធ្វើបត្យាប័នទៅលើបុគ្គលនោះ។

៤. ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជា មិនបានទទួលសំណើសុំធ្វើបត្យាប័ន ពីរដ្ឋធ្វើសំណើ ក្នុងអំឡុងពេល ៦០ថ្ងៃ បន្ទាប់ពីបុគ្គលនោះ ត្រូវបានឃុំខ្លួនតាមដីកា អាជ្ញាធរទទួលបន្ទុកចោទប្រកាន់ត្រូវតែចេញបញ្ជាឲ្យដោះលែងបុគ្គលនោះ។

៥.បុគ្គលដែលត្រូវបានដោះលែង តាមកថាខណ្ឌទី៤ខាងលើនេះ អាចត្រូវចាប់ខ្លួនជាថ្មី ប្រសិនបើរដ្ឋធ្វើសំណើបញ្ជូនសំណើសុំធ្វើបត្យាប័ន បន្ទាប់ពីបុគ្គលនោះ ត្រូវបានដោះលែង។

លើសពីនេះទៅទៀត ក្រមនីតិវិធីព្រហ្មទណ្ឌ ក៏បានបញ្ញត្តិបន្ថែមផងដែរថា ក្នុងករណីចាប់ខ្លួនបុគ្គលដែលគេទាមទារ ត្រូវតែនាំទៅបង្ហាញខ្លួន ក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា ដែលមានសមត្ថកិច្ចខាងដែនដី ហើយត្រូវឲ្យដំណឹងទៅកាន់បុគ្គលនោះ អំពីបញ្ជាឲ្យចាប់ និងឃុំខ្លួន និងទទួលចម្លើយពីបុគ្គលនោះ។ ចំពោះបុគ្គលដែលរដ្ឋធ្វើសំណើទាមទារនោះ ត្រូវផ្ទេរមកឃុំខ្លួន នៅ

ពន្ធនាគារភ្នំពេញ។ បុគ្គលនោះ អាចស្នើសុំឲ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ស្តាប់ចម្លើយខ្លួនបាន។[១០]

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ រៀបចំសំណុំរឿង ដើម្បីប្តឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ។ បុគ្គលនេះអាចមានសិទ្ធិអមដោយមេធាវីដែលខ្លួនជ្រើសរើស ឬមេធាវីដែលត្រូវបានចាត់តាំងដោយអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ រីឯការពិភាក្សាដេញដោល ត្រូវប្រព្រឹត្តិទៅនៅក្នុងបន្ទប់សម្ងាត់។

ម្យ៉ាងវិញទៀត បុគ្គលដែលគេទាមទារអាចមានសិទ្ធិស្នើសុំឲ្យគេដោះលែងឲ្យនៅក្រៅឃុំបាន។ ពាក្យសុំនៅក្រៅឃុំនោះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយដាក់ជូនសភាស៊ើបសួរ និងសម្រេចក្រោយពីបានស្តាប់ចម្លើយបុគ្គលដែលគេទាមទារនោះតាមរយៈសេចក្តីសន្និដ្ឋានប្តឹងសុំរបស់អគ្គព្រះរាជអាជ្ញា និងសេចក្តីសន្និដ្ឋានការពារក្តី របស់មេធាវីនៃជននោះ។[១១]

**ឧទាហរណ៍** ក្នុងសំណុំរឿងព្រហ្មទណ្ឌ(**បត្យាប័ន**)លេខៈ ៣២ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៦ របស់តុលាការកំពូលដដែលខាងលើ បានឲ្យដឹងថាបុគ្គលជនជាតិរុស្ស៊ី ក៏បានដាក់ពាក្យសុំនៅក្រៅឃុំបណ្តោះអាសន្ន ប៉ុន្តែត្រូវបានសភាស៊ើបសួរនៃសាលាឧទ្ធរណ៍សម្រេចមិនព្រមដោះលែងឲ្យនៅក្រៅឃុំឡើយ ដោយសំអាងហេតុថា សំណើសុំធ្វើបត្យាប័នលើបុគ្គលនោះ ត្រូវបានអគ្គព្រះរាជអាជ្ញាធ្វើឡើងត្រឹមត្រូវតាមមាត្រា ៥៧៩ មាត្រា ៥៨០ និងមាត្រា៥៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយបុគ្គលនោះ គ្មានមុខរបរ ទីលំនៅពិតប្រាកដ និងគ្មានសញ្ជាតិខ្មែរទេ និងមិនមែនជាអ្នកនយោបាយទេ ដែលនឹងមានការលំបាកក្នុងការស្វែងរកចាប់ខ្លួន ហេតុនេះការសុំដោះលែងក្រៅឃុំមិនអនុញ្ញាតទេព្រោះគ្មានមូលហេតុត្រឹមត្រូវ ។

[១០] មាត្រា ៥៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧។
[១១] មាត្រា ៥៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧។

## ២.៣. សេចក្តីសម្រេចពីបត្យាប័ន

ករណីនេះ ដូចគ្នាផងដែរជាមួយនឹង ករណីនៃការចាប់ខ្លួន និងការឃុំខ្លួនបណ្តោះអាសន្ន។ ក្នុងករណីដែលរដ្ឋដាក់សំណើ ពុំបានចុះសន្ធិសញ្ញាជាមួយកម្ពុជានោះទេ នោះរាជរដ្ឋាភិបាលកម្ពុជាត្រូវអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ ក្រោយពីបានស្តាប់ចម្លើយរបស់បុគ្គលដែលគេទាមទារ សេចក្តីសន្និដ្ឋានស្នើសុំរបស់អគ្គព្រះរាជអាជ្ញា និងសេចក្តីសន្និដ្ឋានការពារក្តីរបស់មេធាវីរួចមកសភាស៊ើបសួរផ្តល់យោបល់តាមរយៈសាលដីកាដែលមានសំអាងហេតុស្តីពីពាក្យសុំឲ្យធ្វើបត្យាប័ននោះ។[១២] សភាស៊ើបសួរ នឹងផ្តល់យោបល់មិនយល់ព្រម ប្រសិនបើយល់ឃើញថាលក្ខខណ្ឌច្បាប់នៃបត្យាប័នមិនត្រូវបានបំពេញទេ។[១៣]

ប្រសិនបើបុគ្គលដែលគេទាមទារ យល់ព្រមឲ្យគេធ្វើការបញ្ជូនខ្លួន តាមពាក្យសុំរបស់រដ្ឋដាក់សំណើក្រោយពីបានទទួលពត៌មានពេញលេញអំពីផលវិបាកនៃការយល់ព្រមចំពោះបត្យាប័ន នោះសភាស៊ើបសួរត្រូវចុះនិទ្ទេសនេះនៅក្នុងដីការបស់ខ្លួន។ [១៤]

កាលណាយោបល់ និងការសម្រេចរបស់សភាស៊ើបសួរបានក្លាយជាស្ថាពរហើយ សាលដីការបស់សភាស៊ើបសួរ ត្រូវបានជូនដំណឹងភ្លាមដល់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ក្នុងករណីសភាស៊ើបសួរផ្តល់យោបល់ មិនយល់ស្របទេ បត្យាប័ននោះមិនអាចធ្វើទៅបានឡើយ។ បុគ្គលដែលគេទាមទារ ត្រូវបានដោះលែងឲ្យមានសេរីភាពវិញភ្លាម លើកលែងតែបុគ្គលនោះជាកម្មវត្ថុនៃសេចក្តីសម្រេចឲ្យឃុំខ្លួនពីរឿងផ្សេងទៀត។ ប្រសិនបើសភាស៊ើបសួរ បញ្ចេញយោបល់យល់ព្រម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចបញ្ជូនរឿងនេះទៅកាន់រដ្ឋាភិបាល ដើម្បីចេញអនុក្រឹត្យបង្គាប់ឲ្យធ្វើបត្យាប័នចំពោះបុគ្គលដែលគេទាមទារនោះ។ ប្រសិនបើបត្យាប័នត្រូវបានបង្គាប់ហើយ បុគ្គលដែលគេ

---

[១២] មាត្រា ៥៨៥ វាក្យខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧។

[១៣]មាត្រា ៥៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧។

[១៤] មាត្រា ៥៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧។

ទាមទារត្រូវបានប្រគល់ឲ្យដល់រដ្ឋធ្វើសំណើ។ ចំពោះរាល់សោហ៊ុយនៃការធ្វើបត្យាប័ន ជាបន្ទុករបស់រដ្ឋដាក់សំណើ។ នៅពេលបុគ្គលដែលគេទាមទារនោះ ចាកផុតពីដែនដីកម្ពុជា ក្បួនការពារត្រូវទទួលខុសត្រូវដោយរដ្ឋធ្វើសំណើ។ ប្រសិនបើរដ្ឋធ្វើសំណើ មិនបានចាប់ផ្តើមនីតិវិធីធ្វើមាតុភូមិនិវត្តន៍ក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីការជូនដំណឹងអំពីអនុក្រឹត្យបង្គាប់ឲ្យធ្វើបត្យាប័នទេ បុគ្គលដែលគេទាមទារនោះ អាចត្រូវបានដោះលែងឲ្យមានសេរីភាពវិញ។[១៥]

ទោះបីជាយ៉ាងណាក៏ដោយ ច្បាប់ស្តីពីការប្រឆាំងនឹងអំពើភេរវកម្ម ក៏បានបញ្ញត្តិផងដែរទាក់ទងនឹងសេចក្តីសម្រេចពីបត្យាប័ន ប៉ុន្តែពុំបានបញ្ញត្តិពីការសម្រេចធ្វើបត្យាប័ន និងនីតិវិធីនៃការសម្រេចនោះទេ គ្រាន់តែបញ្ជាក់ពីមូលហេតុចាំបាច់សម្រាប់ការបដិសេធសំណើធ្វើបត្យាប័នប៉ុណ្ណោះ។

មាត្រា ៩៨ នៃច្បាប់ស្តីពីការប្រឆាំងអំពើភេរវកម្ម បានបញ្ញត្តិថា៖

១. រាជរដ្ឋាភិបាលកម្ពុជា មិនត្រូវយល់ព្រមតាមសំណើសុំធ្វើបត្យាប័នលើបុគ្គលណាម្នាក់ចំពោះបទល្មើសក្រោមច្បាប់របស់រដ្ឋបរទេស ដែលស្របគ្នានឹងបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះឡើយ ប្រសិនបើយល់ឃើញថា:

ក. សំណើនោះត្រូវបានធ្វើឡើង ដើម្បីកាត់ទោស ឬផ្តន្ទាទោសបុគ្គលណាម្នាក់ ដោយសារតែជាតិសាសន៍ សាសនា សញ្ជាតិ ដើមកំណើត ជាតិពន្ធ ឬទស្សនៈនយោបាយរបស់បុគ្គលនោះ

ខ. ស្ថានភាពរបស់បុគ្គលនោះ អាចត្រូវរងការវិនិច្ឆ័យ ដោយសារតែជាតិសាសន៍ សាសនា សញ្ជាតិ ដើមកំណើត ជាតិពន្ធ ឬទស្សនៈនយោបាយរបស់បុគ្គលនោះ ឬ

[១៥] មាត្រា ៥៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧។

គ. បុគ្គលនោះ ត្រូវបានកាត់ទោសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬរដ្ឋបរទេសណាមួយ ចំពោះបទល្មើសនោះ ហើយសាលក្រមបានចូលជាស្ថាពរ និងត្រូវបានអនុវត្តចំពោះបុគ្គលនោះ

ឃ. បុគ្គលនោះ ត្រូវបានផ្តន្ទាទោស ពីបទល្មើសនោះដោយកំបាំងមុខ និង:

ឃ១. ដោយពុំមានការជូនពត៌មានគ្រប់គ្រាន់អំពីការកាត់ទោសនោះ ឬដោយបុគ្គលនោះ ពុំត្រូវបានផ្តល់ឱកាសឲ្យរៀបចំការពារខ្លួន និង

ឃ២. ដោយបុគ្គលនោះពុំមានឱកាសសុំឲ្យមានការកាត់ទោសករណីនោះឡើងវិញ ដោយមានវត្តមានរបស់ខ្លួន។

២. រាជរដ្ឋាភិបាលកម្ពុជា មិនត្រូវយល់ព្រម តាមសំណើសុំធ្វើបត្យាប័នបុគ្គលណាម្នាក់ ចំពោះបទល្មើសក្រោមច្បាប់របស់រដ្ឋបរទេស ដែលស្របគ្នា នឹងបទល្មើសតាមបញ្ញត្តិនៃច្បាប់នោះឡើយ ប្រសិនបើយល់ឃើញថា នៅពេលប្រគល់ឲ្យទៅរដ្ឋបរទេស បុគ្គលនោះនឹងទទួលរងនូវការធ្វើទារុណកម្ម។

ក្នុងករណីដែលរាជរដ្ឋាភិបាលកម្ពុជា ដោយមូលហេតុណាមួយបដិសេធការធ្វើបត្យាប័នបុគ្គលណាមួយ ទៅឲ្យរដ្ឋធ្វើសំណើ ក្រោយពីពិចារណាសមស្របលើសំណើបត្យាប័ន:

ក. រាជរដ្ឋាភិបាលកម្ពុជា ត្រូវតែបញ្ជូនសំណុំរឿងនេះ ទៅឲ្យអាជ្ញាធរទទួលបន្ទុកចោទប្រកាន់ដើម្បីចោទប្រកាន់ និង

ខ. អាជ្ញាធរទទួលបន្ទុកចោទប្រកាន់ ត្រូវតែធ្វើសេចក្តីសម្រេចចិត្តលើសំណុំរឿងដូចគ្នានឹងករណីនៃបទល្មើសតាមបញ្ញត្តិនៃច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម។[១៦]

[១៦] មាត្រា ៩៩ នៃច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម ដែលប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧។

ក្រៅពីនេះ រាជរដ្ឋាភិបាលកម្ពុជា អាចយល់ព្រម ដោយពុំចាំបាច់ធ្វើចំណាត់ការបត្យាប័នផ្លូវការឡើយ ចំពោះការធ្វើបត្យាប័នបុគ្គលណាមួយ ចំពោះបទល្មើសតាមច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម ប្រសិនបើបុគ្គលនោះយល់ព្រមជាលាយលក្ខណ៍អក្សរ នៅចំពោះមុខតំណាងទទួលខុសត្រូវនៃអាជ្ញាធរទទួលបន្ទុកចោទប្រកាន់ថា សុខចិត្តទទួលរងការធ្វើបត្យាប័នទៅកាន់រដ្ឋធ្វើសំណើចំពោះបទល្មើសនោះ។ ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជា មិនត្រូវយល់ព្រមចំពោះ បត្យាប័នតាមបញ្ញត្តិនៃលក្ខខណ្ឌខាងលើឡើយ លុះត្រាតែៈ

ក. រដ្ឋធ្វើសំណើបានធ្វើសំណើផ្លូវការ សុំធ្វើបត្យាប័នបុគ្គលនោះ និង

ខ. មុនពេលដែលការយល់ព្រមត្រូវបានផ្តល់ ជននោះត្រូវតែបានទទួលពត៌មានពេញលេញអំពីផលវិបាកនៃការយល់ព្រមលើបត្យាប័ន។[១៧]

ជារួមមក នៅពេលមានរដ្ឋបរទេសណាមួយធ្វើសំណើបត្យាប័ន មកកាន់ព្រះរាជាណាចក្រកម្ពុជា គឺត្រូវតែធ្វើឡើងតាមរយៈទូតរបស់ខ្លួនដែលប្រចាំនៅប្រទេសកម្ពុជា។

[១៧] មាត្រា ១០០ នៃច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម ដែលប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក បត្យាប័នគឺសំដៅលើនីតិវិធីមួយ ដែលក្នុងនោះមានរដ្ឋមួយជារដ្ឋធ្វើសំណើ បានធ្វើសំណើលើជនណាម្នាក់ពីរដ្ឋមួយទៀត ដើម្បីនាំយកជននោះមកធ្វើការចោទប្រកាន់ ឬមកផ្តន្ទាទោសតាមយុត្តាធិការ ឬតាមច្បាប់របស់ប្រទេសដាក់សំណើនោះ។ ទន្ទឹមនឹងនេះ បត្យាប័នអាចធ្វើឡើងតាមរយៈ ការព្រមព្រៀងរវាងរដ្ឋ និងរដ្ឋ ដែលការព្រមព្រៀងនេះ អាចធ្វើឡើងតាមរយៈសន្ធិសញ្ញា ឬការព្រមព្រៀងរវាងរដ្ឋដាក់សំណើ និងរដ្ឋទទួលសំណើ។ មិនតែប៉ុណ្ណោះ បត្យាប័នអាចធ្វើទៅបាន អាស្រ័យទៅលើកម្មវត្ថុចម្បងមួយ គឺ **បទល្មើស** ប៉ុន្តែបទល្មើសទាំងអស់ មិនមែនសុទ្ធតែជាកម្មវត្ថុនៃការធ្វើបត្យាប័ននោះទេ។ ក្រៅពីលក្ខខណ្ឌខាងលើ បត្យាប័នក៏ត្រូវគោរពលើលក្ខខណ្ឌនៃសញ្ជាតិរបស់ជនដែលត្រូវស្នើសុំ, ការអនុវត្តនីតិវិធីក្នុងរដ្ឋដាក់សំណើ, គោលការណ៍អាជ្ញាអស់ជំនុំ(គោលការណ៍មិនជំនុំជម្រះក្តីពីរដងលើរឿងតែមួយ) ហើយក៏ត្រូវគោរពទៅតាមទស្សនៈវិស័យផ្នែកមនុស្សធម៌ផងដែរ។

ចំណែកឯនីតិវិធីនៃការធ្វើបត្យាប័ននៅក្នុងព្រះរាជាណាចក្រកម្ពុជា ពុំទាន់មានចែងឲ្យបានច្បាស់លាស់នៅឡើយទេ គឺគ្រាន់តែបានចែងអំពីនីតិវិធីមួយចំនួននៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ និងនៅក្នុងច្បាប់ពិសេសមួយចំនួនដូចជា ច្បាប់ស្តីពីការប្រឆាំងអំពើភេរវកម្មឆ្នាំ២០០៧ប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត ក៏ពុំទាន់មានបទបញ្ញត្តិណាមួយបានចែងអំពីសមត្ថកិច្ចរបស់ស្ថាប័នដែលពាក់ព័ន្ធផងដែរ ដូច្នេះហើយ ទើបការអនុវត្តបត្យាប័ននៅមានភាពខ្វះចន្លោះ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏ការអនុវត្តបត្យាប័ននៅកម្ពុជាអាចដំណើរការទៅបានរហូតមកដល់សព្វថ្ងៃនេះ។ ការអនុវត្តបត្យាប័ននេះ អាចធ្វើទៅបានក៏អាស្រ័យទៅលើស្ថាប័នពាក់ព័ន្ធមួយចំនួនដូចជា ក្រសួងយុត្តិធម៌ តុលាការកំពូល សាលាឧទ្ធរណ៍ ក្រសួងការបរទេស ក្រសួងមហាផ្ទៃ ស្ថានទូត និងសហប្រតិបត្តិការអន្តរជាតិផងដែរ។

ប្រសិនបើប្រទេសកម្ពុជាយើង ដើរតួរជារដ្ឋដាក់សំណើ អាជ្ញាធរកណ្តាលនៃក្រសួងមហាផ្ទៃបានដើរតួរយ៉ាងសំខាន់ ក្នុងការធ្វើសំណើបត្យាប័ន ដើម្បីបញ្ជូនទៅរដ្ឋបរទេស។ ផ្ទុយទៅវិញ ក្នុងករណីដែលប្រទេសកម្ពុជា ជារដ្ឋទទួលសំណើបត្យាប័នវិញ គឺត្រូវមានការចូលរួមយ៉ាងសកម្មពីបណ្តាស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីធ្វើការពិនិត្យទៅលើលក្ខខណ្ឌ និយ័តភាពនៃពាក្យសុំ ព្រមទាំងធ្វើការចាប់ខ្លួន និងឃុំខ្លួន។ ប៉ុន្តែយើងឃើញថា ប្រទេសកម្ពុជាយើងបានបង្កើតនូវក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីជួយសម្រួលដល់ការអនុវត្តបត្យាប័នឲ្យមានភាពរលូន។ ទោះជាយ៉ាងនេះក្តីការបង្កើតក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ មិនទាន់បានធ្វើឲ្យការអនុវត្តបត្យាប័នបានប្រសើរខ្លាំងនោះទេដោយសារតែមានភាពក្មេងខ្ចីនៅឡើយ ប៉ុន្តែក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ ក៏បានធ្វើឲ្យការងារបត្យាប័នបានប្រសើរជាមុនមួយកម្រិតដែរ។

ដោយសារប្រទេសកម្ពុជា ពុំទាន់មានច្បាប់ បទបញ្ញត្តិចែងច្បាស់ទាក់ទងនឹងបញ្ហាបត្យាប័ននេះ ដូចនេះដើម្បីឲ្យស្ថាប័នពាក់ព័ន្ធ និងក្រុមប្រឹក្សាអាជ្ញាកណ្តាល អាចអនុវត្តប្រកបដោយប្រសិទ្ធភាព និងកាន់តែប្រសើរជាងនេះ រាជរដ្ឋាភិបាលគួរតែបង្កើតនូវច្បាប់ដែលចែងច្បាស់លាស់និងល្អិតល្អន់អំពីបញ្ហាបត្យាប័ននេះ ដើម្បីលើកកម្ពស់អភិវឌ្ឍន៍ផ្នែកបត្យាប័ននៅប្រទេសកម្ពុជាប្រកបដោយវឌ្ឍនភាព ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីយើងខ្ញុំទាំងពីរ បានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទនេះមក យើងខ្ញុំទទួលបាននូវបទពិសោធន៍ និងចំណេះដឹងថ្មីៗជាច្រើនពាក់ព័ន្ធនឹងបញ្ហាបត្យាប័ន ជាពិសេសសហប្រតិបត្តិការអន្តរជាតិរបស់ប្រទេសកម្ពុជា ជាមួយនឹងបណ្តារដ្ឋដទៃទៀតនៅលើពិភពលោក។ ទន្ទឹមនឹងនេះដែរ ការស្រាវជ្រាវរបស់យើងខ្ញុំ ក៏បានជួបឧបសគ្គមួយចំនួន ដូចជាមានភាពលំបាកក្នុងការស្វែងរកឯកសារនៅតាមបណ្តាលក្រសួង ស្ថាប័នរដ្ឋ និងស្ថាប័នតុលាការ និងប្រឈមនឹងភាពស្មុគស្មាញមួយចំនួនផងដែរ ប៉ុន្តែយើងខ្ញុំនៅតែព្យាយាមខិតខំប្រមូលឯកសារពាក់ព័ន្ធទាំងឡាយអស់ពីសមត្ថភាពដែលអាចទៅរួច ដើម្បីចងក្រងជាសារណានេះឡើងអោយខានតែបាន។ មិនតែប៉ុណ្ណោះ ដោយសារប្រទេសកម្ពុជា ពុំទាន់មានច្បាប់ស្តីពីបត្យាប័ននៅឡើយ ពោលគឺមានតែក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ពិសេសមួយចំនួនដែលពាក់ព័ន្ធនឹងបត្យាប័នប៉ុណ្ណោះ និងមិនមានចែងឲ្យបានល្អិតល្អន់ទៀតផង ហេតុនេះហើយទើបធ្វើឲ្យការអនុវត្តនៅតាមស្ថាប័នពាក់ព័ន្ធមានការលំបាកច្រើន។

ហេតុដូច្នេះហើយ រាជរដ្ឋាភិបាលកម្ពុជា គប្បីគួរតែបង្កើតឡើងនូវ ច្បាប់ស្តីពីបត្យាប័ន ព្រមទាំងត្រូវចែងលម្អិតអំពីលក្ខខណ្ឌទាំងឡាយ ដែលអាចអនុញ្ញាត ឬមិនអនុញ្ញាតឲ្យធ្វើបត្យាប័ន ក៏ដូចជានីតិវិធី ថែមទាំងកំណត់នូវសមត្ថកិច្ចរបស់ស្ថាប័នពាក់ព័ន្ធផងដែរ។ ការធ្វើដូចនេះ គឺដើម្បីជាគ្រឹះក្នុងការអនុវត្តបត្យាប័នឲ្យមានភាពរលូន និងមានប្រសិទ្ធភាពទៅបានដូចប្រទេសនានាមួយចំនួន។ លើសពីនេះទៅទៀត រដ្ឋាភិបាលគួរបង្កើតការផ្សព្វផ្សាយអំពីបញ្ហាបត្យាប័ន ទៅកាន់ប្រជាជនទូទាំងប្រទេសឲ្យបានជ្រួតជ្រាប និងបានយល់ដឹង ព្រមទាំងធ្វើការណែនាំសន្ធិសញ្ញាគំរូរបស់អង្គការសហប្រជាជាតិ ដូចជា អំពីការបង្កើតកិច្ចព្រមព្រៀង ឬសន្ធិសញ្ញាទ្វេភាគីជាមួយប្រទេសដទៃឲ្យបានកាន់តែច្រើន ដើម្បីបង្កើនគុណភាពនៃការធ្វើបត្យាប័នឲ្យកាន់តែប្រសើរឡើង។

មុននឹងបញ្ចប់ យើងខ្ញុំសូមកោតសរសើរដល់រដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន ដែលបាននិងកំពុងខិតខំបង្កើនគុណភាពនៃធ្វើឲ្យបញ្ញាបត្យាប័ន ពីមួយថ្ងៃទៅមួយថ្ងៃនិយាយដោយឡែក និងបានខិតខំអភិវឌ្ឍន៍លើគ្រប់វិស័យប្រកបដោយសុខសន្តិភាពនិយាយជារួម ។ យើងខ្ញុំសង្ឃឹមថា រដ្ឋាភិ បាល នឹងបន្តធ្វើឲ្យបញ្ញាបត្យាប័ននេះកាន់តែប្រសើរជាងនេះទៀត ដើម្បីឲ្យលើកតម្កើងវិស័យយុត្តិធម៌របស់ប្រទេសយើង លុបបំបាត់ការប្រព្រឹត្តិបទល្មើសឆ្លងដែនឲ្យខានតែបាន និងធ្វើឲ្យប្រទេសកម្ពុជាមានការអភិវឌ្ឍបន្ថែមប្រកបដោយវឌ្ឍនភាព ឧត្តមភាព និងភាពសុខដុមជានិរន្តរ៍។

# ឯកសារយោង

# ឯកសារយោង

១. សន្ធិសញ្ញាទ្វេភាគី ស្តីពីបត្យាប័នរវាង ព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងប្រទេសចំនួនបួន ដូចជា:

-ព្រះរាជាណាចក្រថៃ ដែលអនុម័ត នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៩

-សាធារណរដ្ឋប្រជាមានិតចិន ដែលអនុម័ត នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០០

-សាធារណរដ្ឋប្រជាមានិតឡាវ ដែលអនុម័ត នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥

-សាធារណរដ្ឋសង្គមនិយមវៀតណាម ដែលអនុម័ត នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤

២. អនុសញ្ញាទ្វេភាគី ស្តីពីបត្យាប័នរវាង ព្រះរាជាណាចក្រកម្ពុជា ជាមួយនឹង សាធារណរដ្ឋបារាំង ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥

៣. កិច្ចព្រមព្រៀងទ្វេភាគី ស្តីពីបត្យាប័នរវាង ព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងសាធារណរដ្ឋកូរ៉េ ដែលអនុម័តនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០

៤. សន្ធិសញ្ញាគំរូ ស្តីពីបត្យាប័នរបស់អង្គការសហប្រជាជាតិ ដែលអនុម័តតាមសេចក្តីសម្រេចលេខ ៤៥-១១៦ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩០

៥. ច្បាប់ស្តីពីការអនុម័តយល់ព្រម លើសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើនៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០

៦.កិច្ចព្រមព្រៀងស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកយុត្តិធម៌ ក្នុងវិស័យរដ្ឋប្បវេណីរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម

៧. ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើកាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧

៨.ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រកាសឲ្យប្រើកាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១

៩.ច្បាប់ស្តីពីការប្រឆាំងនឹងអំពើភេរវកម្ម ប្រកាសឲ្យប្រើកាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧

១០. ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពនៃសាលាជម្រះក្តីនៃរដ្ឋកម្ពុជា ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ ១៩៩៣

១១. ច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩២

១២. សៀវភៅស្តីពីបត្យាប័ន ដែលរៀបរៀងដោយ ក្រុមអ្នកច្បាប់សច្ចៈខ្មែរ បោះពុម្ពនៅឆ្នាំ២០១៦

១៣. សៀវភៅស្តីពី នីតិព្រហ្មទណ្ឌទូទៅ របស់លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ បោះពុម្ពឆ្នាំ២០១១

១៤.សៀវភៅ នីតិអន្តរជាតិសាធារណៈរបស់ លោកសាស្ត្រាចារ្យ អ៊ឹង រដ្ឋា បោះពុម្ពឆ្នាំ២០០៤

១៥. សៀវភៅទំនាក់ទំនងអន្តរជាតិ (បញ្ហាពិភពលោក និងកិច្ចសហប្រតិបត្តិការនៅក្នុងរបត់ថ្មីនៃសតវត្សទី២១) របស់បណ្ឌិត វិជ័យ ដែលបោះពុម្ពឆ្នាំ២០១០ ។

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

-ឧបសម្ព័ន្ធទី១ សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយព្រះរាជាណាចក្រថៃ ដែលអនុម័ត នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៩

-ឧបសម្ព័ន្ធទី២ សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយ សាធារណរដ្ឋប្រជាមានិតចិន ដែលអនុម័ត នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០០

-ឧបសម្ព័ន្ធទី៣ សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយ សាធារណរដ្ឋប្រជាមានិតឡាវ ដែលអនុម័ត នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥

-ឧបសម្ព័ន្ធទី៤ សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយ សាធារណរដ្ឋសង្គមនិយមវៀតណាម ដែលអនុម័ត នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤

-ឧបសម្ព័ន្ធទី៥ អនុសញ្ញា ស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយនឹង សាធារណរដ្ឋបារាំង ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥

-ឧបសម្ព័ន្ធទី៦ កិច្ចព្រមព្រៀង ស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយនឹង សាធារណរដ្ឋកូរ៉េដែលអនុម័តនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០

-ឧបសម្ព័ន្ធទី៧ ច្បាប់ស្តីពីការអនុម័តយល់ព្រម លើសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើនៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០

-ឧបសម្ព័ន្ធទី៨ កិច្ចព្រមព្រៀងស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកយុត្តិធម៌ ក្នុងវិស័យរដ្ឋប្បវេណីរវាងប្រទេស កម្ពុជា និងប្រទេសវៀតណាម

-ឧបសម្ព័ន្ធទី៩ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើកាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧

-ឧបសម្ព័ន្ធទី១០ ច្បាប់ស្តីពីការប្រឆាំងនឹងអំពើភេរវកម្ម ប្រកាសឲ្យប្រើកាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧

-ឧបសម្ព័ន្ធទី១១ លិខិត ឬឯកសារផ្សេងៗដែលទាក់ទងនឹងការធ្វើបត្យាប័ន ។